RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ស៊ុយអែត
Sverige

# គោលការណ៍ណែនាំ ស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

កញ្ញា ២០២៣

# គោលការណ៍ណែនាំ
# ស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

# មាតិកា


បុព្វកថា.......................................................................................................................................3

សំណួរសួរញឹកញាប់..........................................................................................................................4

I. សេចក្តីផ្តើមអំពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស.......................................................................4

II. គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស.............................8

III. ការអនុវត្តគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា.......................................................................................................................9

IV. ព័ត៌មានបន្ថែម................................................................................................................................9

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស.................................10

# បុព្វកថា

នៅក្នុងឆ្នាំ 2001 អតីតគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (សព្វថ្ងៃមានឈ្មោះ ជា ក្រុមប្រឹក្សាសិទ្ធិមនុស្ស) បានចាត់វិធានការប្រកបដោយចក្ខុវិស័យ ផ្តោតលើភាពចាំបាច់នៃការបង្កើតគោលការណ៍ស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស។ អស់រយៈពេលជាច្រើនឆ្នាំ កិច្ចខិតខំប្រឹងប្រែងជាសាកលក្នុងការលុបបំបាត់ភាពក្រីក្រ និងភាពក្រីក្រធ្ងន់ធ្ងរ ត្រូវបានមើលឃើញពីភាពជោគជ័យដែលទទួលបានជាចម្បងពីភាពរឹងមាំនៃសេដ្ឋកិច្ចពិភពលោកមានភាពប្រសើរឡើងជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ចំនួនប្រជាជនមួយផ្នែកនៅតែជាប់នៅក្នុងភាពក្រីក្រយ៉ាងគួរឱ្យកត់សម្គាល់ ដោយសារតែបញ្ហារចនាសម្ព័ន្ធដែលមិនមានការឆ្លើយតបតាមវិធីសាស្ត្រសេដ្ឋកិច្ច។ នេះជាមូលហេតុដែលការអនុវត្តសិទ្ធិមនុស្សក្នុងការលុបបំបាត់ភាពក្រីក្របានក្លាយទៅជារបកគំហើញដ៏សំខាន់មួយ។

កថាខណ្ឌទី ១ នៃគោលការណ៍ទាំងនេះគូសបញ្ជាក់ថា "ភាពក្រីក្រធ្ងន់ធ្ងរ គឺជាការបង្ហាញយ៉ាងច្បាស់នៃភាពមិនអាចកាត់ផ្តាច់ពីគ្នា មានទំនាក់ទំនងគ្នា និងការពឹងពាក់គ្នាទៅវិញទៅមកនៃសិទ្ធិមនុស្ស ដោយហេតុថាមនុស្សដែលរស់នៅក្នុងភាពក្រីក្រប្រឈមមុខនឹងការរំលោភសិទ្ធិជាប្រចាំថ្ងៃ ដូចជាសិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម ដែលប្រាស្រ័យទាក់ទង និងពង្រឹងគ្នាទៅវិញទៅមក ដែលអាចនាំឱ្យមានការរងគ្រោះធ្ងន់ធ្ងរ"។ ដូច្នេះហើយ វិធីសាស្ត្រផ្តោតលើសិទ្ធិមនុស្ស ដែលមានចែងក្នុងគោលការណ៍ទាំងនេះ រួមចំណែកដល់ការពង្រឹងសមត្ថភាព និងការកសាងសមត្ថភាពរបស់បុគ្គល តាមរយៈការផ្តល់នូវច្រកចេញពីភាពក្រីក្រ។

ជំងឺរាតត្បាត កូវីត-១៩ បានផ្លាស់ប្តូរភាពវិជ្ជមាននេះ ដោយបង្ករឱ្យមនុស្សជាង ១០០ លាននាក់ធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ កត្តានេះហើយដែលធ្វើឱ្យគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធកាន់តែខ្លាំងឡើង។ តាមរយៈការបកប្រែគោលការណ៍នេះទៅជាច្រើនភាសា អាចផ្តល់ឱ្យអ្នកដែលធ្វើការដោយផ្ទាល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ចូលប្រើប្រាស់បានងាយស្រួល។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស ជាភាសាខ្មែរនេះនឹងចូលរួមចំណែក ក្នុងការជួយទៅដល់កុមារ ស្ត្រី និងបុរសដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះបំផុតទូទាំងប្រទេសកម្ពុជា។



**លោកសាស្ត្រាចារ្យ Morten Kjaerum**

នាយក វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺកច្បាប់សិទ្ធិមនុស្ស និងមនុស្សធម៌

# សំណួរសួរញឹកញាប់

## I. សេចក្តីផ្តើមអំពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

ភាពក្រីក្រ មិនមែនជាបញ្ហាសេដ្ឋកិច្ចតែមួយមុខនោះទេ ប៉ុន្តែជាបាតុភូតពហុភាព ដែលគ្របដណ្តប់លើ បញ្ហាខ្វះខាតទាំងខាងប្រាក់ចំណូល និងសមត្ថភាពចាំបាច់ ក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ បានធ្វើសេចក្តីថ្លែងការណ៍ក្នុងឆ្នាំ2011 ថា ភាពក្រីក្រ គឺជា "លក្ខខណ្ឌដែលមនុស្សរងនូវការដកហូតជាប្រចាំឬយ៉ាងរ៉ាំរ៉ៃ នូវធនធាន សមត្ថភាព ជម្រើស សន្តិសុខ និងអំណាច ដែលចាំបាច់សម្រាប់ការទទួលបានស្តង់ដាររស់នៅសមរម្យ និងសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គមផ្សេងៗទៀត"។ ដោយឡែក ភាពក្រីក្រធ្ងន់ធ្ងរ ត្រូវបានកំណត់និយមន័យដោយអតីតអ្នករាយការណ៍ពិសេសទទួលបន្ទុកភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស កាលពីឆ្នាំ2005 ថា "ជាការរួមផ្សំបញ្ចូលគ្នារវាងភាពក្រីក្រខាងប្រាក់ចំណូល ភាពក្រីក្រខាងផ្នែកអភិវឌ្ឍមនុស្ស និងការផាត់ចេញពីសង្គម" ដែលកង្វះខាតសុវត្ថិភាពជាមូលដ្ឋានក្នុងរយៈពេលវែង ជះឥទ្ធិពលទៅលើទិដ្ឋភាពជាច្រើននៃជីវិតមនុស្ស នៅក្នុងពេលដំណាលគ្នា និងបានធ្វើឱ្យចុះខ្សោយយ៉ាងធ្ងន់ធ្ងរដល់ឱកាសក្នុងការប្រើប្រាស់ និងការទទួលបានឡើងវិញនូវសិទ្ធិនានាក្នុងពេលអនាគតដ៏ខ្លីខាងមុខ"។

### 1. តើភាពក្រីក្រធ្ងន់ធ្ងរបំពានសិទ្ធិមនុស្សដោយរបៀបណា?

ជាទូទៅ ភាពក្រីក្រ គឺជាការរំលោភបំពានសិទ្ធិមនុស្សជាមូលដ្ឋានមួយចំនួន។ ភាពក្រីក្រធ្ងន់ធ្ងរ រឹតតែបំពាន សិទ្ធិមនុស្សកាន់តែខ្លាំង តាមរយៈការបដិសេធនូវការទទួលបានកត្តាចាំបាច់ជាមូលដ្ឋានសម្រាប់ជីវិតរស់នៅ ដូចជាស្បៀងអាហារ ទឹកស្អាត ជម្រក និងការថែទាំសុខភាព។ ភាពក្រីក្រធ្ងន់ធ្ងរ ក៏ប៉ះពាល់សិទ្ធិរបស់មនុស្សក្នុងការទទួលបានការអប់រំ សុខាភិបាល សន្តិសុខសង្គម កិច្ចគាំពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ និងការទទួលបានយុត្តិធម៌ សិទ្ធិសេរីភាពបញ្ចេញមតិ និងសេរីភាពក្នុងការបង្កើតសមាគម សេរីភាពរួចផុតពីការរើសអើង ជាដើម។ ភាពក្រីក្រធ្ងន់ធ្ងរ បង្កឱ្យមានជាវដ្តនៃការដកហូតឬបដិសេធសិទ្ធិ និងការផាត់ចេញពីសង្គម ដែលជាហេតុធ្វើឱ្យមនុស្សពិបាកគេចផុតពីភាពក្រីក្រ និងទទួលបានសក្តានុពលពេញលេញរបស់ខ្លួនណាស់។ ភាពក្រីក្រធ្ងន់ធ្ងរ មិនគ្រាន់តែរាំងមនុស្សម្នាក់ៗពីការបំពេញភារកិច្ចក្នុងនាមជាបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរារាំងពួកគេពីការបំពេញភារកិច្ចជាសមូហភាពក្នុងនាមជាពលរដ្ឋ ឪពុកម្តាយ កម្មករនិយោជិត និងអ្នកបោះឆ្នោតផងដែរ។ ហេតុដូច្នេះ ការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ មិនត្រូវមើលឃើញត្រឹមជាបញ្ហាសប្បុរសធម៌ទេ ប៉ុន្តែជាបញ្ហាសិទ្ធិមនុស្សដែលត្រូវការដោះស្រាយជាបន្ទាន់។

### 2. តើមូលហេតុអ្វីខ្លះដែលបង្កឱ្យមានភាពក្រីក្រធ្ងន់ធ្ងរ?

មូលហេតុដែលបង្កនូវភាពក្រីក្រធ្ងន់ធ្ងរ មានភាពស្មុគស្មាញ លក្ខណៈពហុវិស័យ និងជារឿយៗជាបរិបទជាក់លាក់។ មូលហេតុទាំងនេះ រួមមានកត្តាដូចជាកង្វះប្រាក់ចំណូល និងកង្វះធនធានផលិតកម្មគ្រប់គ្រាន់សម្រាប់ធានាបាននូវជីវភាពប្រកបដោយចីរភាព ឱកាសសេដ្ឋកិច្ចមានកម្រិត ភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ សុខភាពមិនល្អ ការទទួលបានមានកម្រិត ឬកង្វះការទទួលបាននូវការអប់រំ និងសេវាសាធារណៈផ្សេងទៀត ភាពគ្មានផ្ទះសម្បែង និងលំនៅឋានមិនសមរម្យ ព្រមទាំងបរិស្ថានគ្មានសុវត្ថិភាព។ មូលហេតុនៃភាពក្រីក្រធ្ងន់ធ្ងរ អាចជាកត្តាដែលផ្សាភ្ជាប់ទៅនឹងបរិបទសង្គមបែបទូលំទូលាយជាងនេះ ដូចជាការរើសអើង ការផាត់ចេញ វិវាទ និងអំពើហិង្សា បម្រែបម្រួល

អាកាសធាតុ និងអភិបាលកិច្ចមិនល្អ។ កត្តារួមចំណែកលើសពីនេះទៀត គឺកង្វះការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងនៅក្នុងជីវភាពសង្គម ពលរដ្ឋ និងវប្បធម៌។

### 3. តើភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្សមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ?

ភាពក្រីក្រធ្ងន់ធ្ងរ អាចជា*មូលហេតុ*នៃការបំពានសិទ្ធិមនុស្សជាក់លាក់ ឧទាហរណ៍ដូចជា អ្នកក្រីក្រជាច្រើននាក់ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងបរិយាកាសដែលគ្មានសុវត្ថិភាព និងលក្ខខណ្ឌមិនល្អចំពោះសុខភាព។ ទន្ទឹមនឹងនេះផងដែរ ភាពក្រីក្រ ក៏អាចជា*ផលវិបាក*ពីការបំពានសិទ្ធិមនុស្ស ឧទាហរណ៍ដូចជា នៅពេលដែលកុមារមិនអាចគេចផុតពីភាពក្រីក្រ ដោយសារតែពួកគេខ្វះការទទួលបានការអប់រំ។ ចំពោះជនមានពិការភាពដែលពួកគេទំនងជាទទួលរងការប៉ះពាល់ពីលទ្ធផលអវិជ្ជមាននៃសេដ្ឋកិច្ចសង្គម ភាពក្រីក្រអាចនាំឱ្យមានការកើនឡើងដល់ហានិភ័យ និងផលប៉ះពាល់លើពិការភាព។ ដូចគ្នានេះដែរ ពិការភាពអាចបង្កើនដល់ហានិភ័យនៃភាពក្រីក្រ។

### 4. តើភាពក្រីក្រធ្ងន់ធ្ងរប៉ះពាល់ដល់ក្រុមងាយរងគ្រោះដោយរបៀបណា?

ភាពក្រីក្រធ្ងន់ធ្ងរ ប៉ះពាល់ដល់ស្ត្រី និងកុមារ ដោយមិនសមាមាត្រនោះទេ។ ស្ត្រីទំនងជារស់នៅក្នុងភាពក្រីក្រ ច្រើនជាងបុរស ហើយពួកគេជួបប្រទះឧបសគ្គច្រើនជាងក្នុងការទទួលបានការអប់រំ ការថែទាំសុខភាព និងឱកាសខាងសេដ្ឋកិច្ច។ កុមារដែលរស់នៅក្នុងភាពក្រីក្រ ទំនងជាទទួលរងកង្វះអាហារូបត្ថម្ភ ជម្ងឺ និងកង្វះការទទួលបានការអប់រំ និងសេវាមូលដ្ឋានផ្សេងទៀត។ ភាពក្រីក្រធ្ងន់ធ្ងរ បង្កឱ្យមានវិសមភាពយេនឌ័រ និងបំពានសិទ្ធិស្ត្រី និងកុមារ។ បន្ថែមពីលើនេះ ជនពិការ ទំនងជារស់នៅក្នុងភាពក្រីក្រច្រើនជាង ដោយសារតែការរើសអើង និងការរារាំងពីការចូលរួមនៅក្នុងសង្គមលើគ្រប់ទិដ្ឋភាពទាំងអស់ រាប់ចាប់តាំងពីការទទួលបានការអប់រំ ការមានការងារធ្វើ ការថែទាំសុខភាព និងការធ្វើដំណើរ ហើយដែលតាមពិតទៅទិដ្ឋភាពទាំងនេះអាចជួយពួកគេគេចផុតពីភាពក្រីក្រ និងលុបបំបាត់ភាពរើសអើង។ ដូចគ្នានេះដែរ ជនភាគតិច ជនជាតិដើមភាគតិច ទេសន្តរប្រវេសជន ឬជនដែលត្រូវបានបំលាស់ទីដោយបង្ខំ ក៏ជាជនដែលទំនងជារស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ដោយសារតែរបាំងផ្នែកសេដ្ឋកិច្ចសង្គម ការផាត់ចេញ និងការរើសអើង។

### 5. តើភាពក្រីក្រ អត្តសញ្ញាណផ្លូវច្បាប់ និងជនគ្មានសញ្ជាតិ (និបេតិកជន) មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ?

អត្តសញ្ញាណផ្លូវច្បាប់ សំដៅលើការទទួលស្គាល់អត្តិភាពរបស់បុគ្គលស្របតាមច្បាប់ ដោយសម្រួលឱ្យមានការទទួលស្គាល់សិទ្ធិជាក់លាក់ និងតួនាទីភារកិច្ចដែលឆ្លើយតបនឹងសិទ្ធិទាំងនោះ។ ភស្តុតាងនៃអត្តសញ្ញាណផ្លូវច្បាប់មានដូចជាសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណ ជាទូទៅគឺសម្រួលឱ្យមានការទទួលបានសិទ្ធិ សេវាកម្ម និងឱកាសសេដ្ឋកិច្ចសង្គម។ ហេតុដូច្នេះ កង្វះអត្តសញ្ញាណផ្លូវច្បាប់ អាចបង្កើនហានិភ័យនៃភាពក្រីក្រធ្ងន់ធ្ងរ និងជាញឹកញាប់រារាំងមនុស្សពីការទទួលបានការគាំពារសង្គម និងកម្មវិធីសុខុមាលភាព។ ទំនាក់ទំនងអន្តរវិស័យរវាងអត្តសញ្ញាណផ្លូវច្បាប់ និងភាពក្រីក្រ ក៏ត្រូវបានទទួលស្គាល់ផងដែរនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលនាពេលបច្ចុប្បន្ននេះ ស្ថិតក្នុងចំណុចដៅទី16.9 ក្នុងការផ្តល់ "អត្តសញ្ញាណផ្លូវច្បាប់ដល់ប្រជាជនគ្រប់រូប" ត្រឹមឆ្នាំ2030។

ទម្រង់ជាក់លាក់នៃបញ្ហាប្រឈមពាក់ព័ន្ធនឹងអត្តសញ្ញាណផ្លូវច្បាប់ គឺជនគ្មានសញ្ជាតិ។ ជនគ្មានសញ្ជាតិ សំដៅលើបុគ្គលដែលមិនត្រូវបានរដ្ឋ ឬប្រទេសណាមួយទទួលស្គាល់ជាពលរដ្ឋ ស្របតាមអានុភាពនៃច្បាប់រដ្ឋ ឬប្រទេសនោះ។ អ្នកដែលរស់នៅក្នុងស្ថានភាពជាជនគ្មានសញ្ជាតិ ជារឿយៗគឺងាយរងគ្រោះទៅនឹងភាពក្រីក្រ ដោយសារតែ

ពួកគាត់ពិបាកនឹងទទួលបានឱកាសអភិវឌ្ឍន៍ ការគាំពារ និងសេវាមូលដ្ឋាន ដូចជាការថែទាំសុខភាព ការអប់រំ ការងារ និងសេវាសង្គមផ្សេងទៀត។ ស្ថានភាពទាំងនោះ បណ្តាលឱ្យពួកគេទទួលរងនូវហានិភ័យកាន់តែច្រើនឡើង នៃភាពក្រីក្រធ្ងន់ធ្ងរ និងទម្រង់ផ្សេងទៀតនៃការរំលោភបំពានសិទ្ធិមនុស្ស។ ភាពក្រីក្រ ក៏អាចរួមចំណែកដល់ហានិភ័យនៃភាពជាជនគ្មានសញ្ជាតិ តាមរយៈការធ្វើឱ្យបុគ្គលមានការពិបាកក្នុងការទទួលបានឯកសារជាភស្តុតាងដើម្បីបង្កើតសញ្ជាតិ ឬអត្តសញ្ញាណផ្លូវច្បាប់ផ្សេងទៀត ដោយសារតែកង្វះចំណេះដឹងពីលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះ។

### 6. តើសិទ្ធិមនុស្សអាចត្រូវបានការពារសម្រាប់អ្នកដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរបានដោយរបៀបណា?

សិទ្ធិមនុស្សរបស់អ្នកដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ អាចត្រូវបានការពារ តាមរយៈការធានាថា ពួកគេទទួលបានកត្តាចាំបាច់ជាមូលដ្ឋានសម្រាប់ជីវិតរស់នៅ រួមមានស្បៀងអាហារ ទឹកស្អាត ជម្រក និងការថែទាំសុខភាព។ វាក៏តម្រូវឱ្យមានការដោះស្រាយមូលហេតុនៃភាពក្រីក្រ ដូចជាការរើសអើង និងការផាត់ចេញពីសង្គម និងកង្វះការទទួលបានការអប់រំ និងឱកាសសេដ្ឋកិច្ចផងដែរ។ ជាការចាំបាច់ ត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិជាក់លាក់មួយចំនួន ដែលមនុស្សរស់នៅក្នុងភាពក្រីក្រត្រូវទទួលបាន តែនៅមានកម្រិត និងមានការរារាំង ហើយដែលវាពាក់ព័ន្ធនឹងគោលនយោបាយរដ្ឋ ដែលមិនមានគ្រប់គ្រាន់ ដូចជាសិទ្ធិរស់រានមានជីវិត និងបូរណភាពរាងកាយ និងសិទ្ធិទទួលបានការទទួលស្គាល់ជាបុគ្គលស្របតាមច្បាប់។ សិទ្ធិមនុស្ស ត្រូវតែទទួលបានការការពារសម្រាប់មនុស្សគ្រប់រូបដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ដោយមិនប្រកាន់ពីស្ថានភាពសេដ្ឋកិច្ចសង្គម ឬស្ថានភាពគតិយុត្តិនោះទេ។

### 7. តើយើងត្រូវធ្វើអ្វីខ្លះដើម្បីលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ?

ការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ ត្រូវការវិធីសាស្ត្របែបទូលំទូលាយមួយ ដែលផ្អែកលើបទដ្ឋាន និងស្តង់ដារសិទ្ធិមនុស្ស និងដោះស្រាយមូលហេតុចំបងនៃភាពក្រីក្រធ្ងន់ធ្ងរ។ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស អាចរួមបញ្ចូលការវិនិយោគទៅលើការអប់រំ ការបង្កើនឱកាសសេដ្ឋកិច្ច ការដោះស្រាយបញ្ហាផាត់ចេញពីសង្គម និងការរើសអើងនៅក្នុងច្បាប់និងការអនុវត្តជាក់ស្តែង ការលើកកម្ពស់សិទ្ធិមនុស្ស សន្តិភាពនិងសន្តិសុខ ក៏ដូចជា ដោះស្រាយផលប៉ះពាល់សង្គមនិងបរិស្ថាន ដូចជាទាក់ទងនឹងគម្រោងអភិវឌ្ឍន៍នានា និងបម្រែបម្រួលអាកាសធាតុ។ រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិនានា សុទ្ធតែដើរតួនាទីសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរ។

### 8. តើអង្គការសហប្រជាជាតិបានដោះស្រាយភាពក្រីក្រធ្ងន់ធ្ងរដោយរបៀបណា?

ជាយូរមកហើយ ភាពក្រីក្រធ្ងន់ធ្ងរ ត្រូវបានចាត់ទុកថាជាបាតុភូតសេដ្ឋកិច្ចយ៉ាងសំខាន់។ ភាពក្រីក្រធ្ងន់ធ្ងរ ត្រូវបានអង្គការសហប្រជាជាតិដាក់ឱ្យសិក្សាស្រាវជ្រាវដោយឡែកថាជាបញ្ហាសេដ្ឋកិច្ចនិងសង្គម ដែលហេតុនេះហើយបានជាគណៈកម្មាធិការសិទ្ធិមនុស្ស បានដាក់បញ្ហានេះជាដំបូង ក្រោមប្រធានបទស្តីពីការទទួលបានសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌។ នៅឆ្នាំ 1998 គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (អង្គភាពកាន់តំណែងមុនការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្ស) បានបង្កើតអាណត្តិផ្តោតលើបញ្ហាក្នុងយន្តការនីតិវិធីពិសេស និងបានតែងតាំងអ្នករាយការណ៍ពិសេសស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងវិភាគពីបញ្ហានេះ។ ការងាររបស់អាណត្តិតំណាង បានរួមចំណែកក្នុងការបង្កើនការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ថាភាពក្រីក្រធ្ងន់ធ្ងរ គឺជាការបំពានសិទ្ធិមនុស្ស ទាំងមូលហេតុ និងផលវិបាកពីបញ្ហានេះ។ នៅឆ្នាំ 2012 ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តជាឯកច្ឆន្ទទៅលើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស ដោយមានកម្មវត្ថុផ្តល់ជាសេចក្តីណែនាំពីរបៀបអនុវត្តស្តង់ដារសិទ្ធិមនុស្ស ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។

កន្លងមក អង្គការសហប្រជាជាតិបានខិតខំប្រឹងប្រែងជាលក្ខណៈប្រព័ន្ធលើការលុបបំបាត់ភាពក្រីក្រ។ មហាសន្និបាតអង្គការសហប្រជាជាតិ បានប្រកាសពីកម្មវិធីទសវត្សរ៍ការងាររបស់អង្គការសហប្រជាជាតិស្ដីពីការលុបបំបាត់ភាពក្រីក្រ ដែលនាពេលបច្ចុប្បន្ននេះស្ថិតក្នុងទសវត្សរ៍ការងារទី 3 ( ឆ្នាំ 2018-2027)។ នៅឆ្នាំ 2000 សេចក្ដីប្រកាសសហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ បានប្ដេជ្ញាចិត្តក្នុងការលុបបំបាត់ភាពក្រីក្រ ដោយចាប់ផ្ដើមអនុវត្តតាមរយៈគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (MDGs)។ របៀបវារៈឆ្នាំ2030 នាពេលបច្ចុប្បន្នសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទាំង 17 គឺជាគោលដៅជាសកលមួយដែលរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ត្រូវបានរំពឹងថានឹងប្រើនៅក្នុងគោលនយោបាយរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាប្រឈមជាសកល។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី 1 សំដៅបញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ទាំងអស់ ដោយមានគោលដៅជាក់លាក់ក្នុងការបញ្ចប់ភាពក្រីក្រធ្ងន់ធ្ងរ ត្រឹមឆ្នាំ2030។ ក្របខណ្ឌការងារផ្សេងទៀត និងសេចក្ដីថ្លែងការណ៍នយោបាយរបស់ទីភ្នាក់ងារឯកទេសនានារបស់អង្គការសហប្រជាជាតិ រាប់ចាប់ពីបញ្ហាបម្រែបម្រួលអាកាសធាតុ  កសិកម្ម រហូតដល់សន្តិសុខស្បៀងអាហារ សុទ្ធតែរួមបញ្ចូលការប្ដេជ្ញាចិត្តក្នុងការលុបបំបាត់ភាពក្រីក្រ ជាអាទិភាពមួយ។

## II. គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

### 1. តើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្សមានអ្វីខ្លះ?

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស គឺជាបណ្តុំគោលការណ៍ ដែលបង្កើតដោយអង្គការសហប្រជាជាតិក្នុងការដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនិងរ៉ាំរ៉ៃ ដែលកើតមានឡើងជាលទ្ធផលនៃភាពក្រីក្រធ្ងន់ធ្ងរ។ គោលការណ៍ណែនាំទាំងនេះ ចែងពីរបៀបអនុវត្តស្តង់ដារសិទ្ធិមនុស្ស ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ គោលការណ៍ណែនាំនេះ ផ្តល់ជាសេចក្តីណែនាំសម្រាប់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត ពីរបៀបធានាថាសិទ្ធិរបស់មនុស្សដែលរស់នៅក្នុងភាពក្រីក្រ ត្រូវបានគោរព ការពារ និងបំពេញ។ គោលការណ៍ណែនាំ សំដៅលើកកម្ពស់គណនេយ្យភាព និងតម្លាភាពប្រសើរជាងនេះ ក្នុងការខិតខំប្រឹងប្រែងដោះស្រាយបញ្ហាភាពក្រីក្រ និងសិទ្ធិមនុស្ស និងសំដៅលើកទឹកចិត្តឱ្យមានការចូលរួមច្រើនជាងមុនពីសំណាក់អ្នកដែលរស់នៅក្នុងភាពក្រីក្រ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរបស់ពួកគេ។

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស គឺជាការបំពេញបន្ថែមទៅលើលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងទៀត ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ គោលការណ៍ណែនាំនេះ ផ្តល់ជាសេចក្តីណែនាំជាក់លាក់អំពីរបៀបដោះស្រាយទំនាក់ទំនងរវាងភាពក្រីក្រ និងសិទ្ធិមនុស្ស និងគូសបញ្ជាក់ពីសារៈសំខាន់នៃអភិក្រមបែបពេញលេញ និងសមាហរណកម្មជាមួយនឹងសិទ្ធិមនុស្ស រួមមានការរៀបចំ និងការអនុវត្តគោលនយោបាយស្តីពីការកាត់បន្ថយ និងការលុបបំបាត់ភាពក្រីក្រ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ ហេតុដូច្នេះ ការអនុវត្តគោលការណ៍ណែនាំនេះ ត្រូវបានមើលឃើញនៅក្នុងបរិបទជាកាតព្វកិច្ចដែលមានស្រាប់របស់រដ្ឋសមាជិក ស្របតាមច្បាប់អន្តរជាតិ។

### 2. តើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស ស្ថិតក្នុងឋានៈអ្វី?

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស ត្រូវបានអនុម័តជាឯកច្ឆន្ទដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស កាលពីខែកញ្ញា ឆ្នាំ2012 (តាមរយៈសេចក្តីសម្រេចលេខ 21/11)។ ខណៈដែលគោលការណ៍ណែនាំនេះមិនមែនជាឯកសារចងកាតព្វកិច្ចតាមផ្លូវច្បាប់ ការអនុម័តលើគោលការណ៍ណែនាំនេះតំណាងឱ្យការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លារបស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ រួមទាំងប្រទេសកម្ពុជាផងដែរ ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ នៅក្នុងប្រទេសរៀងៗខ្លួន។ ដោយសារ នាពេលបច្ចុប្បន្ន រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ បានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ តាមវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដូច្នេះ វាជាការសំខាន់ដែលរដ្ឋត្រូវដាក់ការប្តេជ្ញាចិត្តនេះទៅជាការអនុវត្តជាក់ស្តែង តាមរយៈការអនុវត្តគោលការណ៍ណែនាំទាំងនេះ នៅក្នុងវិធានការលុបបំបាត់ភាពក្រីក្រទាំងអស់ និងគោលនយោបាយផ្សេងទៀតដែលប៉ះពាល់ដល់សិទ្ធិរបស់មនុស្សដែលរស់នៅក្នុងភាពក្រីក្រ។ ការផ្សព្វផ្សាយទូលំទូលាយស្តីពីគោលការណ៍ណែនាំនេះនៅថ្នាក់ជាតិ ដោយរួមសហការដៃគូជាមួយសង្គមស៊ីវិល គឺជាជំហានសំខាន់មួយនៅក្នុងដំណើរការនេះ។

## III. ការអនុវត្តគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា

### 1. តើគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស មានភាពពាក់ព័ន្ធទៅនឹងបរិបទប្រទេសកម្ពុជាដូម្តេចខ្លះ?

មាត្រា 31 នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងធានាពីការអនុវត្តសន្ធិសញ្ញានានា ស្តីពី សិទ្ធិមនុស្ស។ ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលចំនួន 8 និងផ្តល់សច្ចាប័នលើពិធីសារតាមជម្រើសពាក់ព័ន្ធនឹងសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួនផងដែរ។ ប្រទេសកម្ពុជា ជារដ្ឋភាគីនៃអនុសញ្ញាស្នូលទាំងអស់របស់អង្គការអន្តរជាតិខាងការងារ និងជារដ្ឋភាគីនៃអនុសញ្ញាស្តីពីជនភៀសខ្លួនឆ្នាំ 1951។ លើសពីនេះ ប្រទេសកម្ពុជា ក៏បានបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ2016-2030 និងបានបង្កើតគោលនយោបាយជាតិ និងផែនការសកម្មភាពមួយចំនួនក្នុងការដោះស្រាយភាពក្រីក្រ រួមមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ2019-2023 យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី 4 ឆ្នាំ2018-2022 ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ2016-2025 និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ2003-2005។ ទោះបីជារហូតមកដល់ពេលនេះ នៅមានការខ្វល់ខ្វាយជាច្រើនពីក្របខណ្ឌគតិយុត្តិ និងកាតព្វកិច្ចអន្តរជាតិក៏ដោយ ក៏បទដ្ឋានច្បាប់ និងសិទ្ធិមនុស្សទាំងនេះ ក៏ដូចជាការប្តេជ្ញាចិត្តពាក់ព័ន្ធរបស់ប្រទេសកម្ពុជា បានផ្តល់នូវក្របខណ្ឌល្អប្រសើរ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់អ្នកដែលរស់នៅក្នុងភាពក្រីក្រ រួមមានអ្នកដែលជាជនភាគតិច និងជាក្រុមងាយរងគ្រោះ។ ដោយសារតែមានការប្តេជ្ញាចិត្តតាមផ្លូវច្បាប់ជាលក្ខណៈអន្តរជាតិទាំងនេះ និងច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជា គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស មានលក្ខណៈអនុវត្តបានជាស្រេចនៅប្រទេសកម្ពុជា។

## IV. ព័ត៌មានបន្ថែម

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស (ជាភាសាអង់គ្លេស) អាចរកមើលបានតាមតំណភ្ជាប់នេះ
https://www.ohchr.org/sites/default/files/Documents/Publications/OHCHR_ExtremePovertyandHumanRights_EN.pdf

របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស
https://www.ohchr.org/en/special-procedures/sr-poverty/annual-reports

*ប្រភពផ្សេងទៀតទាក់ទងនឹងភាពក្រីក្រ និងសិទ្ធិមនុស្ស៖*

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR), 'ភាពក្រីក្រ សិទ្ធិទទួលបានស្បៀងអាហារ និងការគាំពារសង្គម': https://www.ohchr.org/en/topic/poverty-right-food-and-social-protection

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR), 'គោលការណ៍ និងសេចក្តីណែនាំសម្រាប់អភិក្រមសិទ្ធិមនុស្សចំពោះយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ':
https://www.ohchr.org/sites/default/files/Documents/Publications/PovertyStrategiesen.pdf

កម្មវិធីទសវត្សរ៍ការងាររបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ភាពក្រីក្រ៖
https://www.un.org/development/desa/socialperspectiveondevelopment/united-nations-decade-for-the-eradication-of-poverty.html

*ច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជាមួយចំនួន ដែលពាក់ព័ន្ធនឹងការលុបបំបាត់ និងការកាត់បន្ថយភាពក្រីក្រ៖*

ក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ2016-2030

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ2019-2023

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី 4 ឆ្នាំ2018-2022

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ2016-2025

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ2003-2005

ផែនការសកម្មភាពជាតិសម្រាប់បញ្ហាប្រឈមគ្រោះអត់ឃ្លានស្មើសូន្យនៅកម្ពុជា (NAP/ZHC 2016-2025)

# គោលការណ៍ណែនាំ
# ស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

# គោលការណ៍ណែនាំ
# ស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស

មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ ត្រូវបានមើលរំលងនិងព្រងើយកន្តើយ ដោយអ្នកនយោបាយ អ្នកផ្តល់សេវា និងអ្នកធ្វើគោលនយោបាយ ដោយសារតែកង្វះសម្លេងនយោបាយ មូលធនហិរញ្ញវត្ថុនិងសង្គម ព្រមទាំងការផាត់ចេញពីសង្គមដ៏រ៉ាំរ៉ៃ។ ពួកគេទទួលរងការរំលោភបំពានសិទ្ធិមនុស្សជាច្រើនដោយអសមាមាត្រ។ ការរើសអើងទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានភាពរីកសាយភាយ និងទទួលបានការសណ្តោសប្រណីយ៉ាងទូលំទូលាយ។

គោលការណ៍ណែនាំស្តីពី ភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្សនេះ គឺជា សេចក្តីណែនាំគោលនយោបាយលក្ខណៈសាកលលើកទីមួយ ដែលផ្តោតជាពិសេសទៅលើ សិទ្ធិមនុស្សរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ គោលការណ៍ណែនាំនេះមានគោលបំណងសម្រាប់ឱ្យរដ្ឋាភិបាលប្រើប្រាស់ ដើម្បីធានាថា គោលនយោបាយសាធារណៈ ដោយរួមបញ្ចូលទាំង កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រដែរនោះ បានទៅដល់សមាជិកក្រីក្របំផុតក្នុងសង្គម គោរពនិងលើកកម្ពស់សិទ្ធិរបស់ពួកគេ ព្រមទាំងពិចារណាទៅលើឧបសគ្គចម្បងៗផ្នែកសង្គម វប្បធម៌ សេដ្ឋកិច្ច និងរចនាសម្ព័ន្ធ ចំពោះការទទួលបានសិទ្ធិមនុស្ស ដែលមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានការប្រឈម។

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តគោលការណ៍ណែនាំស្តីពីភាពក្រីក្រធ្ងន់ធ្ងរនិងសិទ្ធិមនុស្សនេះ ជាឯកច្ឆន្ទតាមរយៈសេចក្តីសម្រេចលេខ 21/11 នៅក្នុងខែកញ្ញា ឆ្នាំ2012។ ការអភិវឌ្ឍគោលការណ៍ណែនាំនេះ ត្រូវបានផ្តួចផ្តើមឡើងដោយអតីតគណៈកម្មាធិការសិទ្ធិមនុស្សក្នុងឆ្នាំ2001 ហើយខ្លឹមសារនៃគោលការណ៍ណែនាំនេះត្រូវបានពិភាក្សានិងចម្រាញ់ អស់រយៈពេលជាងមួយទសវត្សរ៍ តាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋ អង្គការសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងសហគមន៍កំពុងរស់ក្នុងភាពក្រីក្រ។ សេចក្តីព្រាងចុងក្រោយត្រូវបានរៀបចំឡើងដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាតិស្តីពីភាពក្រីក្រធ្ងន់ធ្ងរ និងសិទ្ធិមនុស្ស **ម៉ាកដាឡេណា សេពុលវេដា ខាម៉ូណា** និងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍របស់គាត់ ដែលដាក់ជូនទៅក្នុងសម័យប្រជុំលើកទី 21 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (A/HRC/21/39)។

*សម្រាប់ទិដ្ឋភាពជាប្រវត្តិសាស្ត្រពេញលេញនៃការអភិវឌ្ឍគោលការណ៍ណែនាំនេះ សូមធ្វើការពិគ្រោះជាមួយ ឧបសម្ព័ន្ធ I នៃរបាយការណ៍ជាផ្លូវការដែលអាចរកបាននៅគេហទំព័រ៖*

*http://www.ohchr.org/EN/ Issues/Poverty/Pages/DGPIntroduction.aspx*

# តារាងមាតិកា

I. បុព្វកថា ........ 16

II. វត្ថុបំណង ........ 18

III. គោលការណ៍គ្រឹះ ........ 19

ក. សេចក្ដីថ្លៃថ្នូរ សាកលភាព ភាពមិនអាចញែកដាច់ពីគ្នា អន្តរទំនាក់ទំនង និងអន្តរពំនឹងផ្អែកនៃសិទ្ធិទាំងអស់
ខ. ការទទួលបានសិទ្ធិមនុស្សទាំងអស់ដោយស្មើភាពគ្នាសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ
គ. សមភាពរវាងបុរសនិងស្ត្រី
ឃ. សិទ្ធិកុមារ
ង. ទីភ្នាក់ងារនិងស្វ័យភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ
ច. ការចូលរួមនិងការពង្រឹងភាពអង់អាច
ឆ. តម្លាភាពនិងការទទួលបានព័ត៌មាន
ជ. គណនេយ្យភាព

IV. លក្ខខណ្ឌតម្រូវក្នុងការអនុវត្ត ........ 24

ក. រដ្ឋគួរអនុម័តយុទ្ធសាស្ត្រជាតិគ្រប់ជ្រុងជ្រោយ ដើម្បីកាត់បន្ថយភាពក្រីក្រនិងការផាត់ចេញពីសង្គម
ខ. រដ្ឋគួរធានាថា គោលនយោបាយសាធារណៈ ផ្ដល់អាទិភាពយ៉ាងត្រឹមត្រូវ ដល់មនុស្សកំពុងរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ
គ. រដ្ឋគួរធានាថាសម្ភារៈបរិក្ខារ ទំនិញ និងសេវា ដែលត្រូវការសម្រាប់ការទទួលបានសិទ្ធិមនុស្ស បង្កលក្ខណៈងាយស្រួល អាចរកបាន អាចសម្របតាមស្ថានភាព មានតម្លៃអាចលៃលកបាន និងមានគុណភាពល្អ
ឃ. រដ្ឋគួរធានាឱ្យគោលនយោបាយមានភាពស៊ីសង្វាក់គ្នា

V. សិទ្ធិជាក់លាក់ ........ 27

ក. សិទ្ធិរស់រានមានជីវិតនិងបូរណភាពរាងកាយ
ខ. សិទ្ធិទទួលបានសេរីភាព និងសន្តិសុខបុគ្គល
គ. សិទ្ធិទទួលបានការគាំពារដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ ការទទួលបានយុត្តិធម៌ និងដំណោះស្រាយមានប្រសិទ្ធភាព
ឃ. សិទ្ធិទទួលបានការទទួលស្គាល់ជាបុគ្គលនៅចំពោះមុខច្បាប់
ង. សិទ្ធិឯកជនភាពនិងការគាំពារលំនៅឋាននិងគ្រួសារ
ច. សិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ
ឆ. សិទ្ធិទទួលបានចំណីអាហារនិងអាហារូបត្ថម្ភគ្រប់គ្រាន់
ជ. សិទ្ធិទទួលបានទឹកនិងអនាម័យ
ឈ. សិទ្ធិមានលំនៅឋានសមរម្យ សុវត្ថិភាពនៃការកាន់កាប់ និងការហាមឃាត់ការបណ្ដេញចេញដោយបង្ខំ
ញ. សិទ្ធិទទួលបានស្តង់ដារសុខភាពផ្លូវកាយនិងផ្លូវចិត្ត ឱ្យបានខ្ពស់តាមអាចសម្រេចបាន

ដ. សិទ្ធិទទួលបានការងារនិងសិទ្ធិនៅកន្លែងការងារ
ឋ. សិទ្ធិទទួលបានរបបសន្តិសុខសង្គម
ឌ. សិទ្ធិទទួលបានការអប់រំ
ឍ. សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ និងទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកវិទ្យាសាស្ត្រនិងការអនុវត្តបែបវិទ្យាសាស្ត្រ

VI. កាតព្វកិច្ចនៃជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ 43

VII. តួនាទីរបស់តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសធុរកិច្ច 44

VIII. ការអនុវត្តនិងការតាមដាន 45

IX. ការបកស្រាយ 46

*គោលការណ៍ណែនាំស្តីពីភាពក្រីក្រធ្ងន់ធ្ងរនិងសិទ្ធិមនុស្ស   ត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី27 ខែកញ្ញា ឆ្នាំ2012 នៅក្នុងសេចក្តីសម្រេចលេខ 21/11*

I. បុព្វកថា

នៅក្នុងពិភពលោកមួយដែលកំណត់ដោយកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច មធ្យោបាយបច្ចេកវិទ្យានិង ធនធានហិរញ្ញវត្ថុដែលមិនធ្លាប់មានពីមុនមក ប៉ុន្តែបែរជាមានមនុស្សជាច្រើនលាននាក់កំពុងរស់ក្នុងភាពក្រីក្រ ធ្ងន់ធ្ងរ គឺជាភាពរន្ធត់ផ្នែកសីលធម៌។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើការយល់ដឹងថា ការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ មិនមែនគ្រាន់តែជាភារកិច្ចផ្នែកសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាកាតព្វកិច្ចតាមផ្លូវ ច្បាប់ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានជាធរមាន។ ហេតុដូច្នេះហើយ បទដ្ឋាននិងគោលការណ៍នៃច្បាប់ សិទ្ធិមនុស្សគួរដើរតួនាទីចម្បងមួយ ក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ និងជាមគ្គុទ្ទេសក៍សម្រាប់គោលនយោបាយ សាធារណៈទាំងអស់ ដែលប៉ះពាល់ទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

ភាពក្រីក្រមិនមែនត្រឹមតែជាបញ្ហាផ្នែកសេដ្ឋកិច្ចតែមួយមុខនោះទេ ប៉ុន្តែវាគឺជាបាតុភូតពហុភាពដែលគ្រប ដណ្តប់លើ បញ្ហាខ្វះខាតទាំងខាងប្រាក់ចំណូល និងសមត្ថភាពចាំបាច់ ក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ បានធ្វើសេចក្តីថ្លែងការណ៍ក្នុងឆ្នាំ2011 ថា ភាពក្រីក្រ គឺជា "លក្ខខណ្ឌដែលមនុស្សរងនូវការដកហូតជាប្រចាំឬយ៉ាងរ៉ាំរ៉ៃ នូវធនធាន សមត្ថភាព ជម្រើស សន្តិសុខ និងអំណាច ដែលចាំបាច់សម្រាប់ការទទួលបានស្តង់ដារស់នៅសមរម្យ និងសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិ នយោបាយ និងសិទ្ធិសង្គមផ្សេងៗទៀត (E/C.12/2001/10, កថា. 8)។ ចំនែកឯ ភាពក្រីក្រធ្ងន់ធ្ងរវិញ ត្រូវបានគេ ផ្តល់និយមន័យថា គឺ "ការរួមផ្សំបញ្ចូលគ្នារវាងភាពក្រីក្រខាងប្រាក់ចំណូល ភាពក្រីក្រខាងផ្នែកអភិវឌ្ឍមនុស្ស និង ការផាត់ចេញពីសង្គម" (A/HRC/7/15, កថា. 13) ដែលកង្វះខាតសុវត្ថិភាពជាមូលដ្ឋានក្នុងរយៈពេលវែង ជះឥទ្ធិ ពលទៅលើទិដ្ឋភាពជាច្រើននៃជីវិតមនុស្ស នៅក្នុងពេលដំណាលគ្នា និងបានធ្វើឱ្យចុះខ្សោយយ៉ាងធ្ងន់ធ្ងរដល់ ឱកាសក្នុងការប្រើប្រាស់ និងក្នុងការទទួលបានឡើងវិញនូវសិទ្ធិនានាក្នុងអនាគតដ៏ខ្លីខាងមុខ (សូមមើលឯកសារ E/ CN.4/Sub.2/1996/13)។

ភាពក្រីក្រ គឺជាក្តីបារម្ភផ្នែកសិទ្ធិមនុស្សជាបន្ទាន់មួយរួចជាស្រេចទៅហើយ។ ភាពក្រីក្រ គឺជាបុព្វហេតុនិង ជាផលវិបាកនៃការរំលោភបំពានសិទ្ធិមនុស្ស និងជាលក្ខខណ្ឌអំណោយផលមួយ សម្រាប់ការរំលោភបំពានផ្សេង ទៀត។ ភាពក្រីក្រធ្ងន់ធ្ងរ មិនមែនមានត្រឹមតែការកំណត់លក្ខណៈថាជាការពង្រឹងគ្នាទៅវិញទៅមកនៃការរំលោភ បំពានទៅលើសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំង ថា មនុស្សដែលកំពុងរស់នៅក្នុងភាពក្រីក្រ ជាទូទៅ ជួបបទពិសោធន៍នៃការបដិសេធការផ្តល់ឱ្យនូវសេចក្តីថ្លៃថ្នូរ និងសមភាព ជាប្រចាំ។

មនុស្សដែលរស់ក្នុងភាពក្រីក្រ ត្រូវប្រឈមមុខនឹងឧបសគ្គធ្ងន់ធ្ងរបំផុតទាំងខាងផ្លូវកាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម ដើម្បីទទួលបានសិទ្ធិនិងសិទ្ធិអំណាចទាំងឡាយ។ ជាលទ្ធផល ពួកគេជួបប្រទះនូវការដកហូតដែល ពង្រឹងគ្នាទៅវិញទៅមក និងមានការពាក់ព័ន្ធគ្នាទៅវិញទៅមកជាច្រើន ដោយរួមមានទាំងលក្ខខណ្ឌការងារដែល មានគ្រោះថ្នាក់ លំនៅឋានមិនមានសុវត្ថិភាព កង្វះម្ហូបអាហារដែលមានជីវជាតិ ការទទួលបានយុត្តិធម៌ដោយពុំស្មើ ភាពគ្នា កង្វះអំណាចនយោបាយ និងការទទួលបានការថែទាំសុខភាពតិចតួច ដែលជាការរារាំងពួកគេពីការសម្រេច បាននូវសិទ្ធិរបស់ខ្លួន ព្រមទាំងធ្វើឱ្យភាពក្រីក្រនៅតែបន្តកើតមាន។ មនុស្សដែលជួបបទពិសោធន៍នៃភាពក្រីក្រ

ធ្ងន់ធ្ងរ រស់នៅក្នុងវដ្តដ៏អាក្រក់មួយនៃភាពគ្មានអំណាច ការប្រមាថមាក់ងាយក្នុងសង្គម ការរើសអើង ការផាត់ចេញពីសង្គម និងការដកហូតផ្នែកសម្ភារៈ ហើយដែលទាំងអស់នេះ ពង្រឹងឱ្យគ្នាទៅវិញទៅមក។

ភាពក្រីក្រធ្ងន់ធ្ងរ មិនមែនជៀសមិនរួចនោះទេ។ យ៉ាងហោចណាស់ក្នុងចំណែកណាមួយនោះ ភាពក្រីក្រធ្ងន់ធ្ងរនេះត្រូវគេបង្កើតឡើង ត្រូវគេជំរុញឱ្យកើតឡើង និងបន្តឱ្យកើតមានមិនដាច់ ដោយសារតែទង្វើឬការមិនធ្វើអ្វីមួយរបស់រដ្ឋ ព្រមទាំងតួអង្គផ្នែកសេដ្ឋកិច្ចផ្សេងទៀត។ នៅក្នុងអតីតកាល គោលនយោបាយសាធារណៈ ជារឿយៗខកខានមិនបានទៅដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរនោះទេ ដែលជាហេតុបណ្តាលឱ្យមានការបន្តភាពក្រីក្រនេះពីជំនាន់មួយទៅជំនាន់មួយទៀត។ វិសមភាពដែលមានលក្ខណៈជារចនាសម្ព័ន្ធនិងជាប្រព័ន្ធ រួមមានផ្នែកសង្គម នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ជារឿយៗ នៅមិនទាន់ត្រូវបានដោះស្រាយ ហើយកាន់តែបង្កភាពញាំញីទៅដល់ភាពក្រីក្របន្ថែមទៀត។ កង្វះភាពស៊ីសង្វាក់ផ្នែកគោលនយោបាយនៅកម្រិតជាតិនិងកម្រិតអន្តរជាតិ ជាញឹកញយ បានធ្វើឱ្យចុះខ្សោយឬប្រទាញប្រទង់ជាមួយនឹងការប្តេជ្ញាចិត្តដើម្បីលុបបំបាត់ភាពក្រីក្រ។

ការដែលថាភាពក្រីក្រធ្ងន់ធ្ងរ មិនមែនជៀសមិនរួច មានន័យថា យើងអាចរកបាននូវ ឧបករណ៍នានាសម្រាប់បញ្ចប់ភាពក្រីក្រធ្ងន់ធ្ងរ។ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ផ្តល់នូវក្របខណ្ឌមួយសម្រាប់ការលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ រយៈពេលវែង ដោយផ្អែកលើការទទួលស្គាល់ថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ គឺជា ម្ចាស់សិទ្ធិ និងជាភ្នាក់ងារនៃការផ្លាស់ប្តូរផងដែរ។

វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គោរពដល់សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងជួយពង្រឹងអំណាចរបស់ពួកគេឱ្យចូលរួមពេញលេញនិងដោយប្រសិទ្ធភាពនៅក្នុងជីវភាពសាធារណៈ ដោយរួមបញ្ចូលទាំងការរៀបចំបង្កើតគោលនយោបាយសាធារណៈ និងធ្វើឱ្យអាជ្ញាធរ មានគណនេយ្យភាព។ បទដ្ឋាន ដែលបានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ តម្រូវឱ្យរដ្ឋពិចារណាកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់ខ្លួន នៅពេលបង្កើត និងអនុវត្តគោលនយោបាយដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

ទោះបីជាមនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ មិនអាចបន្ថយមកបញ្ចូលក្នុងបញ្ជីក្រុមងាយរងគ្រោះក៏ដោយ ក៏ការរើសអើងនិងការផាត់ចេញពីសង្គម ស្ថិតនៅក្នុងចំណោមបុព្វហេតុ និងផលវិបាកចម្បងៗនៃភាពក្រីក្រដែរ។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ បានជួបប្រទះនូវបទពិសោធជាគុណវិបត្តិនិងការរើសអើង ដោយសារមូលហេតុពូជសាសន៍ យេនឌ័រ អាយុ ជាតិពិន្ទុ សាសនា ភាសា ឬឋានៈផ្សេងទៀត។ ជាញឹកញយ ស្ត្រីជួបប្រទះនូវបញ្ហាប្រឈមកាន់តែច្រើន នៅក្នុងការទទួលបានប្រាក់ចំណូល ទ្រព្យសម្បត្តិ និងសេវាកម្មនានា ហើយមានភាពងាយរងគ្រោះដោយឡែក ចំពោះភាពក្រីក្រធ្ងន់ធ្ងរនេះ ដូចជាក្រុមកុមារ ក្រុមមនុស្សចាស់ ក្រុមមនុស្សមានពិការភាព ជនចំណាកស្រុក ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន មនុស្សរត់គេចខ្លួនដើម្បីសុវត្ថិភាព និគមជនភាគតិច មនុស្សរស់នៅជាមួយជំងឺ/មេរោគអេដស៍ និងជនជាតិដើមភាគតិច។

ខណៈដែលរដ្ឋគឺជាអ្នកទទួលខុសត្រូវក្នុងការសម្រេចឱ្យបាននូវសិទ្ធិមនុស្សនោះ តួអង្គផ្សេងទៀត រួមមានទាំងអង្គការអន្តរជាតិ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ អង្គការសង្គមស៊ីវិល និងសហគ្រាសធុរកិច្ច ក៏មានការទទួលខុសត្រូវចំពោះសិទ្ធិរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រផងដែរ។ រដ្ឋត្រូវតែបង្កើតបរិយាកាសអំណោយផលមួយ ដែលលើកទឹកចិត្តនិងលើកកម្ពស់សមត្ថភាពរបស់បុគ្គល អង្គការតាមសហគមន៍ ចលនាសង្គម និងអង្គការមិនមែន

រដ្ឋាភិបាលដទៃទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ព្រមទាំងពង្រឹងភាពអង់អាចដល់មនុស្សដែលកំពុងរស់ក្នុងភាពក្រីក្រឱ្យទាមទារសិទ្ធិរបស់ខ្លួន។

រដ្ឋដែលសកម្មក្នុងការគិតគូរាប់បញ្ចូលមនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរទៅក្នុងច្បាប់ និងស្ថាប័ននានានឹងទទួលបានអត្ថប្រយោជន៍ពីការចូលរួម និងការរួមចំណែកផ្នែកសង្គម ពីប្រជាជនទាំងមូលរបស់ខ្លួន។ សហគមន៍អន្តរជាតិក៏នឹងទទួលបានអត្ថប្រយោជន៍ នៅពេលដែលរដ្ឋកាន់តែច្រើនជានាបាននូវភាពសុខដុមផ្នែកសង្គម ស្តង់ដារស់នៅកាន់តែប្រសើរសម្រាប់ប្រជាពលរដ្ឋដែលជាអ្នកក្រីក្របំផុត និងពង្រឹងភាពអង់អាច និងសមាហរណកម្មមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទៅក្នុងប្រព័ន្ធនៃសិទ្ធិនិងកាតព្វកិច្ច។

## II. វត្ថុបំណង

ផ្លែផ្កាដែលកើតចេញមកពីការពិគ្រោះយោបល់ អស់រយៈពេលជាច្រើនឆ្នាំ ជាមួយភាគីរដ្ឋ និងភាគីពាក់ព័ន្ធដទៃទៀត ដោយរួមបញ្ចូលទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រផងនោះ វត្ថុបំណងនៃគោលការណ៍ណែនាំនេះគឺដើម្បីផ្តល់នូវសេចក្តីណែនាំអំពីរបៀបអនុវត្តស្តង់ដារសិទ្ធិមនុស្ស នៅក្នុងកិច្ចប្រឹងប្រែងដើម្បីប្រឆាំងនឹងភាពក្រីក្រ។ គោលការណ៍ណែនាំទាំងនេះ មានបំណងធ្វើជាឧបករណ៍មួយសម្រាប់រៀបចំបង្កើតនិងអនុវត្តគោលនយោបាយកាត់បន្ថយនិងលុបបំបាត់ភាពក្រីក្រ ព្រមទាំងជាមគ្គុទ្ទេសក៍អំពីរបៀបដែលត្រូវគោរព ការពារ និងបំពេញសិទ្ធិមនុស្សរបស់អ្នកកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ នៅគ្រប់វិស័យទាំងអស់នៃគោលនយោបាយសាធារណៈ។ ដោយមានមូលដ្ឋានលើបទដ្ឋាននិងគោលការណ៍សិទ្ធិមនុស្សដែលមានការព្រមព្រៀងគ្នាជាលក្ខណៈអន្តរជាតិ គោលការណ៍ណែនាំនេះរចនាឡើងដោយផ្អែកលើឧបករណ៍អន្តរជាតិ និងកិច្ចព្រមព្រៀងថ្នាក់តំបន់ រួមមាន សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព និងជាបន្ថែមទៀតគឺ សេចក្តីពន្យល់រួមនិងអនុសាសន៍ទូទៅរបស់ស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិ។ គោលការណ៍ណែនាំនេះ ផ្តល់ការណែនាំសម្រាប់ការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សនៅក្នុងសេចក្តីសម្រេចគោលនយោបាយ នៅកម្រិតជាតិនិងកម្រិតអន្តរជាតិ រួមទាំង សេចក្តីសម្រេចពាក់ព័ន្ធនឹងជំនួយអន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដូច្នេះ ការអនុវត្តគោលការណ៍ណែនាំ គួរចាត់ទុកថា ស្ថិតនៅក្នុងបរិបទនៃកាតព្វកិច្ចជាធរមានរបស់រដ្ឋទាំងឡាយ ក្រោមច្បាប់អន្តរជាតិ។

គោលការណ៍ណែនាំនេះ មានវិសាលភាពជាសាកល។ គោលការណ៍ណែនាំ គួរត្រូវបានប្រើប្រាស់ដោយប្រទេសទាំងអស់ និងតំបន់ទាំងអស់ នៅគ្រប់ដំណាក់កាលទាំងអស់នៃការអភិវឌ្ឍសេដ្ឋកិច្ច ដោយអាស្រ័យទៅលើស្ថានភាពជាក់លាក់នានានៅថ្នាក់ជាតិ។ គោលការណ៍ណែនាំទាំងនេះ ផ្អែកលើទិដ្ឋភាពទំនាក់ទំនង និងពហុភាពនៃភាពក្រីក្រ ដែលត្រូវបានទទួលស្គាល់ថា ការពង្រឹងភាពអង់អាចរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ គួរប្រើជាមធ្យោបាយទាំងក្នុងការសម្រេចបាននូវសិទ្ធិរបស់ជនក្រីក្រ និងបញ្ចប់ភាពក្រីក្រ។

មនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានបទពិសោធន៍និងតម្រូវការផ្សេងគ្នា ព្រមទាំងបានជួបប្រទះនូវកម្រិតនៃភាពក្រីក្រផ្សេងគ្នា ទាក់ទងនឹងកម្រិតនៃភាពធ្ងន់ធ្ងរ និងថេរៈវេលានៃភាពក្រីក្រនោះ។ ខណៈដែលមនុស្សទាំងអស់

ក្នុងស្ថានភាពបែបនេះ គួរតែជាចំណុចផ្តោតនៃគោលនយោបាយនានាដែលផ្អែកទៅលើសិទ្ធិមនុស្ស គោលការណ៍ណែនាំទាំងនេះផ្តោតការបារម្ភជាចម្បងទៅលើអ្នកដែលទទួលរងបទពិសោធនៃភាពក្រីក្រធ្ងន់ធ្ងរបំផុតនៅក្នុងបរិបទណាមួយ[1]។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ គឺជាក្តីបារម្ភជាក់លាក់ ដោយសារតែការទុកចោល ការផាត់ចេញ និងការប្រមាថនៅក្នុងសង្គមដែលជារឿយៗ មានន័យថា មិនមានគោលនយោបាយសាធារណៈ ឬសេវាសាធារណៈបានទៅដល់ពួកគេប្រកបដោយប្រសិទ្ធភាពនោះទេ។ ឧបសគ្គ អសន្តិសុខ និងកត្តាជាច្រើនសម្ព័ន្ធនានា ជារឿយៗបានធ្វើឱ្យពួកគេមិនអាចអះអាងទាមទារសិទ្ធិរបស់ខ្លួន និងបំពេញសក្តានុពលរបស់ខ្លួនដោយឯករាជ្យបានទេ គឺថាពួកគេត្រូវការការគាំទ្រដោយសកម្មពីរដ្ឋ និងភាគីពាក់ព័ន្ធដទៃទៀត។

## III. គោលការណ៍គ្រឹះ

គោលការណ៍ខាងក្រោមនេះ មានសារៈសំខាន់ចាំបាច់ណាស់ចំពោះវិធីសាស្ត្រដែលផ្អែកលើសិទ្ធិមនុស្ស និងត្រូវតែផ្តល់ជាគ្រឹះសម្រាប់ការរៀបចំបង្កើតនិងការអនុវត្តរាល់គោលនយោបាយសាធារណៈទាំងអស់ ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ឬដែលប៉ះពាល់ដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

### ក. សេចក្តីថ្លៃថ្នូរ សាកលភាព ភាពមិនអាចញែកដាច់ពីគ្នា អន្តរទំនាក់ទំនង និងអន្តរពំនឹងផ្អែកនៃសិទ្ធិទាំងអស់

សេចក្តីថ្លៃថ្នូររបស់មនុស្ស គឺជាគ្រឹះដ៏សំខាន់បំផុតនៃសិទ្ធិមនុស្ស។ សេចក្តីថ្លៃថ្នូរនេះ ផ្សាភ្ជាប់នឹងគោលការណ៍សមភាព និងការមិនរើសអើង ដោយមិនអាចផ្តាច់ពីគ្នាបាន។ ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ត្រូវតែតម្កល់ក្នុងរាល់គោលនយោបាយសាធារណៈទាំងអស់។ ភ្នាក់ងាររដ្ឋនិងបុគ្គលឯកជន ត្រូវតែគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សទាំងអស់គ្នា ត្រូវតែជៀសវាងការធ្វើឱ្យមានការប្រមាថមាក់ងាយក្នុងសង្គម និងបុរេនិច្ឆ័យ ព្រមទាំងទទួលស្គាល់ និងគាំទ្រដល់កិច្ចប្រឹងប្រែងនានា ដែលមនុស្សកំពុងរស់ក្នុងភាព ក្រីក្រកំពុងធ្វើ ដើម្បីកែលម្អជីវិតរបស់ខ្លួន។

ភាពក្រីក្រធ្ងន់ធ្ងរ បង្ហាញយ៉ាងច្បាស់អំពីភាពមិនអាចចែកដាច់ពីគ្នា អន្តរទំនាក់ទំនង និងអន្តរពំនឹងផ្អែកនៃសិទ្ធិមនុស្ស ដោយសារថា មនុស្សដែលរស់នៅក្នុងភាពក្រីក្រ ជារៀងរាល់ថ្ងៃ ប្រឈមមុខនឹងការរំលោភបំពានលើសិទ្ធិពលរដ្ឋ សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គមរបស់ខ្លួន ដែលមានអន្តរកម្មនិងពង្រឹងគ្នាទៅវិញទៅមក ពីសិទ្ធិមួយទៅសិទ្ធិមួយទៀត ដោយបង្កនូវផលប៉ះពាល់ដែលមានលក្ខណៈបំផ្លិចបំផ្លាញបំផុត។

រដ្ឋត្រូវតែបង្កើតបរិយាកាសអំណោយផលដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ព្រមទាំងការពារសិទ្ធិមនុស្ស។ គោលនយោបាយសាធារណៈក្នុងការជម្នះភាពក្រីក្រ ត្រូវតែផ្អែកទៅលើការគោរព ការការពារ និងការបំពេញរាល់សិទ្ធិមនុស្សទាំងអស់របស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយស្មើភាពគ្នា។ ពុំត្រូវមានគោលនយោបាយណាមួយនៅក្នុងវិស័យណាក៏ដោយ ដែលធ្វើឱ្យស្ថានភាពនៃភាពក្រីក្រកាន់តែអាក្រក់ឡើង ឬមានផលប៉ះពាល់អវិជ្ជមានដោយអសមាមាត្រទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រនោះទេ។

### ខ. ការទទួលបានសិទ្ធិមនុស្សទាំងអស់ដោយស្មើភាពគ្នាសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ

[1] *ក្នុងន័យនេះ ពាក្យ "ភាពក្រីក្រ" នៅក្នុងអត្ថបទតទៅនេះ គួរត្រូវបានយល់ន័យថា "ភាពក្រីក្រធ្ងន់ធ្ងរ" ទោះបីជាវាមិនត្រូវបានបកស្រាយដោយចង្អុលបង្ហាញថា កាតព្វកិច្ចឬអនុសាសន៍ជាក់លាក់មិនអាចអនុវត្តទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រជាទូទៅក៏ដោយ។*

18. ការរើសអើង គឺជាបុព្វហេតុផង និងជាផលវិបាកនៃភាពក្រីក្រផង។ ជារឿយៗ ភាពក្រីក្រកើតចេញមកពីការអនុវត្តដែលមានការរើសអើង ទាំងដោយបើកចំហនិងដោយលាក់កំបាំង។ ប្រជាជនកំពុងរស់នៅក្នុងភាពក្រីក្រ ក៏ទទួលរងនូវឥរិយាបថរើសអើង និងការប្រមាថមាក់ងាយ ពីអាជ្ញាធរសាធារណៈនិងតួអង្គឯកជន ដោយសារតែភាពក្រីក្ររបស់ពួកគេតែម្យ៉ាងគត់។ ដូច្នេះហើយ ប្រជាជនកំពុងរស់ក្នុងភាពក្រីក្រ ទំនងជាទទួលរងនូវបទពិសោធន៍ក្នុងទម្រង់នៃការរើសអើងដែលមានលក្ខណៈប្រសព្វគ្នាច្រើនយ៉ាង ដោយមានរួមទាំងការគិតទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេផង។

19. រដ្ឋត្រូវធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានភាពស្មើគ្នានៅចំពោះមុខច្បាប់ និងក្រោមច្បាប់ ព្រមទាំងមានសិទ្ធិទទួលបានការការពារនិងទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នាពីច្បាប់ ដោយគ្មានការរើសអើង។ រដ្ឋត្រូវតែលុបចោល ឬកែប្រែច្បាប់ និងបទប្បញ្ញត្តិ ដែលមានភាពលំអៀងប្រឆាំងនឹងសិទ្ធិ ផលប្រយោជន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរស់ក្នុងភាពក្រីក្រ។ ការរើសអើងគ្រប់ទម្រង់នៃបទប្បញ្ញត្តិ ឬបែបបទរដ្ឋបាល ដោយផ្ទាល់ ឬដោយប្រយោល ដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពសេដ្ឋកិច្ច ឬដោយហេតុផលផ្សេងទៀតទាក់ទងនឹងភាពក្រីក្រត្រូវតែកំនត់រកអោយឃើញ និងលុបបំបាត់ចោល។

20. សមភាពនិងការមិនរើសអើង គឺជាកាតព្វកិច្ចជាធរមានភ្លាមៗនិងជាអន្តរវិស័យ ដែលត្រូវតែបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះរាល់វិធានការទាំងអស់ដែលចាត់ឡើងដោយភាគីពាក់ព័ន្ធ ទាក់ទងទៅនឹងប្រជាជនកំពុងរស់ក្នុងភាពក្រីក្រ។ កាតព្វកិច្ចទាំងអស់នេះ តម្រូវឱ្យរដ្ឋកំណត់រកឱ្យឃើញនូវក្រុមដែលងាយរងគ្រោះនិងរងនូវគុណវិបត្តិនៅក្នុងសង្គម ព្រមទាំងដោយចាត់ជាកត្តាអាទិភាព ធានាថា ក្រុមប្រជាជនទាំងអស់នេះទទួលបាននូវសិទ្ធិមនុស្សដោយឈរលើមូលដ្ឋានស្មើភាពគ្នា។ រដ្ឋមានកាតព្វកិច្ចក្នុងការចាត់វិធានការពិសេសនិងវិជ្ជមាន ដើម្បីកាត់បន្ថយឬលុបបំបាត់លក្ខខណ្ឌដែលបណ្តាលឱ្យមានការរើសអើងឬជួយធ្វើឱ្យការរើសអើងកើតមានបន្ត។

21. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានសិទ្ធិទទួលបានការការពារពីការប្រមាថមាក់ងាយអវិជ្ជមានដែលភ្ជាប់ទៅនឹងលក្ខខណ្ឌនៃភាពក្រីក្រ។ រដ្ឋត្រូវតែហាមឃាត់អាជ្ញាធរសាធារណៈ ទោះជានៅថ្នាក់ជាតិឬថ្នាក់មូលដ្ឋាន ពីការប្រមាថមាក់ងាយឬរើសអើងទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ហើយត្រូវតែចាត់រាល់វិធានការសមស្របទាំងឡាយដើម្បីកែតម្រូវគំរូខាងសង្គមវប្បធម៌ ជាមួយនឹងទស្សនៈអំពីការលុបបំបាត់បុរេនិច្ឆ័យនិងផ្នត់គំនិតនានា។ រដ្ឋត្រូវតែដាក់ឱ្យអនុវត្តនូវកម្មវិធីអប់រំដោយឡែក សម្រាប់មន្ត្រីសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការមិនរើសអើងប្រឆាំងនឹងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

22. ត្រូវចាប់យកវិធានការវិជ្ជមាន ដើម្បីធានាសមភាពនៅក្នុងការអនុវត្តជាក់ស្តែងទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ វិធានការបែបនេះ គួររួមបញ្ចូល ឧបករណ៍សម្រាប់នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ រដ្ឋបាល ថវិកា និងបទប្បញ្ញត្តិនានា ព្រមទាំងគោលនយោបាយ កម្មវិធី និងសកម្មភាពវិជ្ជមានជាក់លាក់ នៅក្នុងវិស័យដែលមានភាពរសើបចំពោះភាពក្រីក្រ ដូចជាការផ្តល់ការងារ ការមានលំនៅឋាន ចំណីអាហារ សន្តិសុខសង្គម ទឹក និងអនាម័យ សុខភាព ការអប់រំ វប្បធម៌ និងការចូលរួមក្នុងជីវភាពសាធារណៈ។

## គ. សមភាពរវាងបុរសនិងស្ត្រី

23. ស្ត្រីមានភាពតំណាងដោយអសមាមាត្រ នៅក្នុងចំណោមអ្នកក្រីក្រ ដោយសារតែទម្រង់នៃការរើសអើង មានលក្ខណៈពហុវិស័យនិងកើនផ្គុំគ្នា ដែលពួកគេបានទទួលរង។ រដ្ឋមានកាតព្វកិច្ច ក្នុងការលុបបំបាត់ការរើសអើងលើស្ត្រី ទាំងក្នុងច្បាប់និងក្នុងការអនុវត្តជាក់ស្តែង ព្រមទាំងដាក់ចេញនូវវិធានការដើម្បីសម្រេចបានសមភាពរវាងបុរសនិងស្ត្រី។

24. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក៏តម្រូវឱ្យរដ្ឋចាត់វិធានការដើម្បីលុបបំបាត់ការអនុវត្តតាមវប្បធម៌និងប្រពៃណីដែលបង្កទុក្ខទោស ព្រមទាំង លុបបំបាត់នូវការអនុវត្តផ្សេងទៀតដែលផ្អែកទៅលើគំនិតអំពីភាពតូចទាប ឬភាពខ្ពង់ខ្ពស់របស់ភេទណាមួយ ឬផ្អែកទៅលើតួនាទីរបស់បុរសនិងស្ត្រីតាមរយៈផ្នត់គំនិតនោះ។ ការអនុវត្តទាំងអស់នេះ ធ្វើឱ្យកើនឡើងនូវការផាត់ចេញពីសង្គមទៅលើស្ត្រីនិងក្មេងស្រី ការរារាំងដល់ការទទួលបានធនធាននិងការអប់រំ ព្រមទាំងធ្វើឱ្យភាពក្រីក្រនិងការរើសអើងនៅតែបន្តកើតមាន។

25. រដ្ឋត្រូវតែចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ។ ស្ត្រីកំពុងរស់ក្នុងភាពក្រីក្រ ហើយជាជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ ប្រឈមនឹងការលំបាកជាក់លាក់នានា នៅក្នុងការទទួលបានយុត្តិធម៌និងនៅក្នុងការចាកចេញពីទំនាក់ទំនងហិង្សានោះ។

26. ស្ត្រីត្រូវតែទទួលបានឱកាសសេដ្ឋកិច្ចស្មើភាពគ្នា។ រដ្ឋត្រូវតែផ្តល់អាទិភាពចំពោះការពង្រីកការទទួលបានការងារ និងឱកាសសហគ្រិនភាពសម្រាប់ស្ត្រី លើកកម្ពស់ការងារសមរម្យ និងការងារផលិតកម្មមានចំណូល ព្រមទាំងកែលម្អការទទួលបានហិរញ្ញវត្ថុ។ គោលនយោបាយសាធារណៈ និងបទប្បញ្ញត្តិស្តីពី ការផ្តល់ការងារ ត្រូវតែពិចារណាទៅលើការលំបាកផ្នែកពេលវេលារបស់ស្ត្រី និងបង្កលក្ខណៈឱ្យស្ត្រីនិងបុរសអាចមើលថែទាំគ្រួសាររបស់ខ្លួនផងដែរ។

27. រដ្ឋត្រូវតែធានា ឱ្យស្ត្រីមានសមត្ថភាពពេញលេញនិងស្មើភាពគ្នាតាមផ្លូវច្បាប់ ក្នុងការធ្វើជាម្ចាស់ ក្នុងការចាត់ចែង និងក្នុងការគ្រប់គ្រងធនធានសេដ្ឋកិច្ច ដូចជា ដីធ្លី ឥណទាន និងមរតក។

28. ស្ត្រីត្រូវតែទទួលបានដោយស្មើភាពគ្នានូវអំណាចនៃការធ្វើសេចក្តីសម្រេច។ រដ្ឋត្រូវតែបង្កើតយន្តការដើម្បីជម្រុញឱ្យមានការចូលពាក់ព័ន្ធពីស្ត្រី ដោយមានរួមទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ នៅក្នុងជីវភាពនយោបាយនិងស្ថាប័នធ្វើសេចក្តីសម្រេច នៅគ្រប់កម្រិតទាំងអស់។

29. គោលនយោបាយត្រូវតែលើកកម្ពស់សមភាពយេនឌ័រក្នុងអាពាហ៍ពិពាហ៍និងទំនាក់ទំនងគ្រួសារ ព្រមទាំងធានាថា ការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី ដោយរួមបញ្ចូលទាំងការធ្វើសេចក្តីសម្រេចទាក់ទងទៅនឹងចំនួនកូននិងការពន្យារកំណើតផងនោះ អាចធ្វើឡើងដោយសេរីនិងមិនមានការរឹតត្បិត និងធានាថា ចំណីអាហារនិងធនធានដទៃទៀត ត្រូវបានបែងចែកដោយស្មើភាពគ្នាក្នុងគ្រួសារ។

30. ត្រូវតែមានការធានាថា ស្ត្រីទទួលបានសេវាសាធារណៈដោយស្មើភាពគ្នា ដោយរួមមានទាំង សេវាសុខភាព អប់រំ និងសេវាគាំពារសង្គម ព្រមទាំងសមភាពនៅក្នុងទីផ្សារការងារ ដោយរួមបញ្ចូលទាំងប្រាក់ឈ្នួល លក្ខខណ្ឌ

ការងារ និងអត្ថប្រយោជន៍សន្តិសុខសង្គម ដោយស្មើភាពគ្នា។ ដោយឡែក សេវានិងព័ត៌មានសុខភាពផ្លូវភេទនិងបន្តពូជ ការអប់រំនៅវ័យកុមារ និងការអប់រំក្រោយបឋមសិក្សា ត្រូវតែបង្កើតឱ្យមានសម្រាប់ស្ត្រីនិងក្មេងស្រី។

31. រដ្ឋត្រូវបង្ហាញឱ្យឃើញច្បាស់អំពីសមភាពយេនឌ័រ ថាជាគោលដៅនៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រថវិកា កម្មវិធី និងគម្រោងនានា។ រដ្ឋត្រូវបង្កើតធនធានថ្នាក់ជាតិដោយផ្តោតឱ្យចំគោលដៅ និងបង្កើនជំនួយអភិវឌ្ឍន៍ជាផ្លូវការ ដើម្បីសមភាពយេនឌ័រ និងយកចិត្តទុកដាក់ទៅលើការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងបរិបទនៃពាណិជ្ជកម្មអន្តរជាតិ។

### ឃ. សិទ្ធិកុមារ

32. ដោយសារថា មនុស្សភាគច្រើនដែលកំពុងរស់ក្នុងភាពក្រីក្រ គឺជាកុមារ និងដោយសារថា ភាពក្រីក្រនៅក្នុងវ័យកុមារ គឺជាឫសគល់នៃភាពក្រីក្រនៅពេលពេញវ័យនោះ សិទ្ធិកុមារត្រូវតែគិតគូជាអាទិភាព។ សូម្បីតែការដកហូតឬការផាត់ចេញក្នុងរយៈពេលខ្លីណាមួយ ក៏អាចបង្កអន្តរាយយ៉ាងខ្លាំងនិងមិនអាចត្រឡប់វិញបាន ចំពោះសិទ្ធិកុមារក្នុងការរស់រានមានជីវិតនិងក្នុងការអភិវឌ្ឍន៍ដែរ។ ដើម្បីលុបបំបាត់ភាពក្រីក្រ រដ្ឋត្រូវតែចាត់វិធានការជាបន្ទាន់ក្នុងការលុបបំបាត់ភាពក្រីក្រក្នុងកុមារភាព។

33. រដ្ឋត្រូវតែធានាថាកុមារទាំងអស់ទទួលបានដោយស្មើភាពគ្នានូវសេវាជាមូលដ្ឋាន ដោយមានទាំងនៅក្នុងរង្វង់គ្រួសារផងដែរ។ នៅក្នុងកម្រិតអប្បបរមា កុមារត្រូវមានសិទ្ធិទទួលបានកញ្ចប់សេវាសង្គមជាមូលដ្ឋាន ដែលរួមមានការថែទាំសុខភាពដែលមានគុណភាពខ្ពស់ ចំណីអាហារសមស្រប លំនៅឋាន ទឹកផឹកមានសុវត្ថិភាព និងអនាម័យព្រមទាំងការអប់រំបឋមសិក្សា ដើម្បីជួយឱ្យពួកគេអាចលូតលាស់ពេញសក្តានុពលរបស់ខ្លួន ជៀសផុតពីជំងឺ កង្វះអាហារូបត្ថម្ភ អនក្ខរកម្ម និងការដកហូតដទៃទៀត។

34. ភាពក្រីក្រ ធ្វើឱ្យកុមារ ជាពិសេសកុមារី ងាយរងគ្រោះចំពោះការកេងប្រវ័ញ្ច ការព្រងើយកន្តើយ និងការរំលោភបំពាន។ រដ្ឋត្រូវតែគោរពនិងលើកកម្ពស់សិទ្ធិរបស់កុមារកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលទាំងតាមរយៈការពង្រឹងនិងការបែងចែកផ្តល់ធនធានចាំបាច់ទៅក្នុងយុទ្ធសាស្ត្រនិងកម្មវិធីគាំពារកុមារ ដោយផ្តោតដាក់លាក់ជាពិសេស ទៅលើកុមារដែលត្រូវគេទុកចោល ដូចជាកុមារនៅតាមដងផ្លូវ ទាហានកុមារ កុមារមានពិការភាព ជនរងគ្រោះដោយសារអំពើជួញដូរ កុមារជាមេគ្រួសារ និងកុមាររស់នៅតាមមជ្ឈមណ្ឌលផ្តល់ការថែទាំ ដែលពួកគេទាំងអស់ស្ថិតនៅក្នុងហានិភ័យខ្ពស់បំផុតនៃការកេងប្រវ័ញ្ចនិងការរំលោភបំពាន។

35. រដ្ឋត្រូវលើកកម្ពស់សិទ្ធិកុមារ ឱ្យមានសម្លេងនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលទាក់ទងទៅនឹងជីវិតរស់នៅរបស់ពួកគេ។

### ង. ទីភ្នាក់ងារ និងស្វ័យភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ

36. មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ ត្រូវតែមានការទទួលស្គាល់ និងត្រូវបានចាត់ទុកជាភ្នាក់ងារសេរី និងស្វ័យភាព។ រាល់គោលនយោបាយទាំងអស់ដែលពាក់ព័ន្ធទៅនឹងភាពក្រីក្រ ត្រូវតែមានគោលបំណងពង្រឹងភាពអង់អាចដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ គោលនយោបាយទាំងអស់នេះ ត្រូវតែផ្អែកទៅលើការទទួលស្គាល់សិទ្ធិរបស់មនុស្សទាំងអស់នេះ ដើម្បីឱ្យពួកគេធ្វើសេចក្តីសម្រេចដោយខ្លួនឯង និងគោរពចំពោះសមត្ថភាពរបស់

ពួកគេនៅក្នុងការបំពេញសក្តានុពលរបស់ខ្លួន ការយល់ឃើញអំពីសេចក្តីថ្លៃថ្នូរនិងសិទ្ធិរបស់ខ្លួនក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តនានាដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគេ។

## ច. ការចូលរួមនិងការពង្រឹងភាពអង់អាច

37. ការចូលរួមដែលមានប្រសិទ្ធភាពនិងមានអត្ថន័យពេញលេញ គឺជាការបញ្ជាក់អំពីសិទ្ធិរបស់បុគ្គលគ្រប់រូបនិងក្រុមនានា ក្នុងការចូលរួមអនុវត្តកិច្ចការសាធារណៈ។ វាក៏ជាមធ្យោបាយមួយក្នុងការលើកកម្ពស់បរិយាប័ន្នសង្គមនិងជាធាតុផ្សំដ៏មានសារៈសំខាន់ចាំបាច់ ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការប្រឆាំងនឹងភាពក្រីក្រ តាមរយៈការធានាថាគោលនយោបាយសាធារណៈមាននិរន្តរភាព និងរៀបចំបង្កើតឡើងដើម្បីបំពេញតាមតម្រូវការដែលបានលើកឡើងដោយប្រជាជនដែលស្ថិតនៅក្នុងចំណែកក្រីក្របំផុតក្នុងសង្គម។

38. រដ្ឋត្រូវតែធានាឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានការចូលរួមដោយសកម្ម ដោយសេរី ទទួលបានព័ត៌មានគ្រប់គ្រាន់ និងមានអត្ថន័យពេញលេញ នៅគ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំបង្កើត ការអនុវត្ត ការតាមដានឃ្លាំមើល និងការវាយតម្លៃ ទៅលើសេចក្តីសម្រេចនិងគោលនយោបាយដែលប៉ះពាល់ដល់ពួកគេ។ ចំណុចនេះទាមទារឱ្យមានការកសាងសមត្ថភាពនិងការអប់រំផ្នែកសិទ្ធិមនុស្ស សម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងការបង្កើតយន្តការនិងការរៀបចំផ្នែកស្ថាប័នជាក់លាក់មួយចំនួន នៅកម្រិតផ្សេងៗគ្នានៃការធ្វើសេចក្តីសម្រេច ដើម្បីជម្នះឧបសគ្គដែលប្រជាជនទាំងនេះប្រឈមមុខ ទាក់ទងទៅនឹងការចូលរួមដោយប្រសិទ្ធភាព។ គួរចាត់វិធានការថែទាំជាពិសេស ដើម្បីបញ្ចូលអ្នកក្រីក្របំផុត និងមនុស្សដែលត្រូវបានគេផាត់ចេញពីសង្គមបំផុតឱ្យចូលរួមបានពេញលេញ។

39. រដ្ឋត្រូវតែធានាថា ក្រុមដែលមានហានិភ័យខ្ពស់ក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ ដោយរួមមានទាំង អ្នកដែលជាជម្មតាទទួលរងនូវគុណវិបត្តិនិងការរើសអើង ដោយសារមូលហេតុ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឋានៈកំណើត ឬឋានៈផ្សេងទៀត មិនត្រឹមតែបានមានភាពតំណាងគ្រប់គ្រាន់នៅរាល់ដំណើរការធ្វើសេចក្តីសម្រេចទាំងឡាយដែលប៉ះពាល់ដល់ពួកគេនោះទេ ប៉ុន្តែ ថែមទាំងត្រូវទទួលបាននូវការពង្រឹងភាពអង់អាចនិងការគាំទ្រដើម្បីសម្តែងទស្សនៈរបស់ពួកគេទៀតផង។

40. រដ្ឋត្រូវតែធានាថាជនជាតិដើមភាគតិច ដែលងាយនឹងរងនូវភាពក្រីក្រជាពិសេសនោះ ទទួលបានសិទ្ធិក្នុងការផ្តល់ការយល់ព្រមដោយសេរី ជាមុន និងមានព័ត៌មានគ្រប់គ្រាន់ តាមរយៈស្ថាប័នតំណាងរបស់ខ្លួន ទាក់ទងទៅនឹងសេចក្តីសម្រេចទាំងអស់ អំពីការប្រើប្រាស់ដីធ្លី ដែនដី និងធនធានរបស់ខ្លួន ពីភាគីរដ្ឋនិងតួអង្គមិនមែនរដ្ឋ។

41. រដ្ឋក៏ត្រូវតែសកម្មក្នុងការការពារបុគ្គល អង្គការសហគមន៍ ចលនាសង្គម ក្រុមនិងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ដែលគាំទ្រ និងតស៊ូមតិដើម្បីសិទ្ធិរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## ឆ. តម្លាភាពនិងការទទួលបានព័ត៌មាន

42. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ ខ្វះការទទួលបានព័ត៌មានសំខាន់ៗ អំពីការសម្រេចដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ បញ្ហានេះនាំទៅដល់ការកាត់បន្ថយប្រាក់ចំណូលសរុបរបស់ពួកគេ រារាំងពួកគេពីការទទួល

បានសេវាសង្គមឬឱកាសការងារ និងពួកគេត្រូវប្រឈមនឹងអំពើពុករលួយ និងការកេងប្រវ័ញ្ចដោយអសមាមាត្រទៀតផង។

43. រដ្ឋត្រូវតែធានាថា សេវាសាធារណៈនិងកម្មវិធីសាធារណៈដែលប៉ះពាល់ដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ត្រូវបានរៀបចំបង្កើតឡើងនិងអនុវត្តប្រកបដោយតម្លាភាព។ រដ្ឋត្រូវតែផ្តល់ព័ត៌មានដែលបង្កលក្ខណៈងាយស្រួល និងមានភាពគ្រប់គ្រាន់តាមវប្បធម៌ផ្សេងៗ អំពីសេវាសាធារណៈទាំងអស់ដែលមនុស្សកំពុងរស់ក្នុងភាពក្រីក្រ អាចរកបាននិងព័ត៌មានអំពីសិទ្ធិរបស់ពួកគេទាក់ទងនឹងសេវាទាំងអស់នោះ។ ព័ត៌មាននេះ គួរតែធ្វើការផ្សព្វផ្សាយយ៉ាងសកម្មតាមរយៈមធ្យោបាយទាំងអស់ដែលអាចរកបាន។

44. រដ្ឋត្រូវតែធានាថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានសិទ្ធិជាបុគ្គល និងសិទ្ធិចូលរួមជាមួយអ្នកដទៃជាសមាគមន៍ ដើម្បីស្វែងរក ទទួល និងចែករំលែកព័ត៌មានអំពីរាល់ការសម្រេចនានាដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ពួកគេ។ ចំណុចនេះ រួមបញ្ចូលទាំងការទទួលបានព័ត៌មានអំពីការអនុវត្តសិទ្ធិនិងសេរីភាព និងការទទួលសំណងដំណោះស្រាយនៅពេលមានការរំលោភបំពាន។

### ជ. គណនេយ្យភាព

45. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ ត្រូវបានគេមើលឃើញថា ជាជនអសកម្មដែលរង់ចាំតែទទួលជំនួយរដ្ឋាភិបាល និងសប្បុរសធម៌ផ្សេងទៀត ដែលតាមពិតទៅ ពួកគេគឺជាម្ចាស់សិទ្ធិដែលមានសិទ្ធអំណាច ដែលអ្នកធ្វើគោលនយោបាយ និងមន្ត្រីសាធារណៈ ត្រូវមានគណនេយ្យភាពចំពោះពួកគេ។

46. រដ្ឋត្រូវធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានសិទ្ធិទទួលបានសំណងប្រកបដោយប្រសិទ្ធភាព តាមរយៈយន្តការតុលាការ ដំណើរការកាត់ក្តីដែលទទួលស្គាល់តាមច្បាប់ រដ្ឋបាល និងនយោបាយ នៅពេលមានសកម្មភាព និងការលុបចោលណាមួយ ដែលធ្វើឱ្យចុះខ្សោយឬធ្វើឱ្យអន្តរាយដល់សិទ្ធិមនុស្សរបស់ពួកគេ ដោយរួមមានទាំងការផ្តល់សេវាសាធារណៈ កម្មវិធីកាត់បន្ថយភាពក្រីក្រ និងការបែងចែកផ្តល់ធនធាន។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រគួរទទួលបានព័ត៌មានពេញលេញអំពី សំណងដំណោះស្រាយដែលពួកគេអាចរកបាន ហើយយន្តការទាំងនេះ គួរតែបង្កលក្ខណៈងាយស្រួលទាំងផ្នែករូបវន្ត និងហិរញ្ញវត្ថុសម្រាប់មនុស្សទាំងអស់គ្នា។

47. រដ្ឋត្រូវតែដាក់ឱ្យអនុវត្តនូវនីតិវិធីនានា ដោយរួមបញ្ចូលទាំងយន្តការបណ្តឹងសមស្រប និងបង្កលក្ខណៈងាយស្រួល ដើម្បីទប់ស្កាត់ កំណត់រកឱ្យឃើញ និងប្រឆាំងតបតទៅនឹងអំពើពុករលួយ ជាពិសេសនៅក្នុងកម្មវិធីសង្គម និងកម្មវិធីផ្សេងទៀត ដែលប៉ះពាល់ដោយផ្ទាល់ទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## IV. លក្ខខណ្ឌតម្រូវក្នុងការអនុវត្ត

48. រដ្ឋជាប់កាតព្វកិច្ចភ្លាមៗនៅក្នុងការចាត់វិធានការ ឆ្ពោះទៅសម្រេចឱ្យបានពេញលេញ ចំពោះសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ហើយច្បាប់សិទ្ធិមនុស្សទាមទារថា យ៉ាងហោចណាស់ កម្រិតសំខាន់ចាំបាច់ជាអប្បបរមានៃសិទ្ធិទាំងអស់ ជានិច្ចកាលគួរតែត្រូវបានធានា។ ប្រសិនបើមានការលំបាកខាងផ្នែកធនធាន ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពិតជាបានអនុញ្ញាតឱ្យមានការសម្រេចបានតាមភាពរីកចម្រើនជាលំដាប់ ចំពោះទិដ្ឋភាពមួយចំនួននៃសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ក្នុងរយៈពេលសមស្របណាមួយ ព្រមទាំងដោយមានសូចនាករដែល

កំណត់ត្រឹមត្រូវ ទោះបីជាវិធានការដែលមានចរិកលក្ខណៈធាក់ថយ មានពន្យល់ចេតនាច្បាស់លាស់ អាចយកមកប្រើបាន គឺតែក្នុងករណីលើកលែងមួយចំនួន និងដោយឈរលើមូលដ្ឋានបណ្ដោះអាសន្នតែប៉ុណ្ណោះ។ នៅគ្រប់ពេលវេលាទាំងអស់ រដ្ឋត្រូវបង្ហាញអំពីវិធានការជាក់លាក់ ដែលបានដាក់ចេញ ដើម្បីដោះស្រាយភាពក្រីក្រនិងបញ្ជាក់ថារដ្ឋបានធ្វើបែបនោះ ដល់កម្រិតអតិបរមានៃធនធានដែលអាចរកបាន ដោយរួមបញ្ចូលទាំងតាមរយៈជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិផង។

49. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ អាចទទួលបានយ៉ាងហោចណាស់នៅកម្រិតសំខាន់ចាំបាច់ក្នុងកម្រិតអប្បបរមា នៃសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ គឺមិនមែនគ្រាន់តែជាការអនុវត្តគោលនយោបាយបច្ចុប្បន្នឱ្យបានកាន់តែពេញលេញនោះទេ។ ការលុបបំបាត់ភាពក្រីក្រ ទាមទារឱ្យមានគោលនយោបាយដែលដោះស្រាយជាក់លាក់ទៅលើស្ថានភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ តាមរយៈក្របខណ្ឌទូលំទូលាយនិងស៊ីសង្វាក់គ្នាដែលគ្របដណ្ដប់ទៅលើរាល់វិស័យទាំងអស់នៃគោលនយោបាយសាធារណៈ និងវិធានការលក្ខណៈនយោបាយ។

## ក. រដ្ឋគួរអនុម័តយុទ្ធសាស្ត្រជាតិគ្រប់ជ្រុងជ្រោយ ដើម្បីកាត់បន្ថយភាពក្រីក្រនិងការផាត់ចេញពីសង្គម

50. រដ្ឋគួរបង្កើតនិងអនុម័តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដោយផ្អែកទៅលើសិទ្ធិមនុស្ស ដែលមានការចូលរួមយ៉ាងសកម្មពីបុគ្គលនិងក្រុមនានា ជាពិសេសមនុស្សកំពុងរស់ក្នុងភាពក្រីក្រ នៅក្នុងការរៀបចំបង្កើតនិងការអនុវត្ត។ យុទ្ធសាស្ត្រនេះ គួរបញ្ចូលចំណុចគោលដៅដែលត្រូវកំណត់ពេលវេលាអនុវត្ត និងមានគ្រោងការអនុវត្តច្បាស់លាស់ ដោយគិតពិចារណាទៅដល់ភាពជាប់ទាក់ទងនឹងថវិកាចាំបាច់។ យុទ្ធសាស្ត្រនេះគួរតែកំណត់ចាត់តាំង អាជ្ញាធរនិងទីភ្នាក់ងារដែលទទួលខុសត្រូវយ៉ាងច្បាស់លាស់ក្នុងការអនុវត្ត និងបង្កើតយន្តការបណ្ដឹងនិងដំណោះស្រាយសមស្រប នៅក្នុងករណីមិនមានភាពអនុលោម។

## ខ. រដ្ឋគួរធានាថា គោលនយោបាយសាធារណៈ ផ្ដល់អាទិភាពយ៉ាងត្រឹមត្រូវ ដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ

51. នៅពេលរៀបចំបង្កើតនិងអនុវត្តគោលនយោបាយសាធារណៈ និងបែងចែកផ្ដល់ធនធាន រដ្ឋគួរគិតគូផ្ដល់អាទិភាពជាចម្បង ចំពោះសិទ្ធិមនុស្សរបស់ក្រុមដែលទទួលរងនូវគុណវិបត្តិបំផុត ជាពិសេសមនុស្សកំពុងរស់ក្នុងភាពក្រីក្រធ្ងន់ធ្ងរ។

52. រដ្ឋគួរធានាថា ការរៀបចំបង្កើត និងការអនុវត្តគោលនយោបាយសាធារណៈ ដោយរួមមានទាំងវិធានការថវិកានិងវិធានការសារពើពន្ធប្រចាំឆ្នាំ ពិចារណាទៅលើទិន្នន័យដែលមានការបែងចែកតាមប្រភេទ និងព័ត៌មានបច្ចុប្បន្នភាព អំពី ភាពក្រីក្រ។

53. រដ្ឋគួរធ្វើឱ្យប្រាកដថា បានកៀងគរធនធានគ្រប់គ្រាន់ និងត្រូវបានប្រើប្រាស់ ដើម្បីធានាធ្វើឱ្យសម្រេចបានសិទ្ធិមនុស្សរបស់អ្នកកំពុងរស់ក្នុងភាពក្រីក្រ។ គោលនយោបាយសារពើពន្ធប្រចាំឆ្នាំ ដោយរួមបញ្ចូលទាំងទាក់ទងទៅនឹងការប្រមូលថវិកា ការបែងចែកផ្ដល់ថវិកា និងការចំណាយផ្សេងៗ ត្រូវតែអនុលោមតាមស្តង់ដារនិងគោលការណ៍សិទ្ធិមនុស្ស ជាពិសេស សមភាព និងការមិនរើសអើង។

54. ដោយសារតែការជះផលប៉ះពាល់ដោយអសមាមាត្រ និងការបង្កអន្តរាយ កើតឡើងពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើក្រុមដែលងាយរងគ្រោះបំផុតទៅនឹងភាពក្រីក្រនោះ រដ្ឋត្រូវតែមានការប្រុងប្រយ័ត្នជាពិសេស ដើម្បីធានាថា វិធានការស្តារវិបត្តិឡើងវិញ រួមទាំងការកាត់បន្ថយចំណាយសាធារណៈ មិនបដិសេធ ឬបំពានទៅលើសិទ្ធិមនុស្សរបស់ក្រុមទាំងនោះទេ។ វិធានការទាំងឡាយត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងគ្មានការរើសអើង។ រដ្ឋត្រូវតែធានាឱ្យមានហិរញ្ញវត្ថុដែលមាននិរន្តរភាពសម្រាប់ប្រព័ន្ធគាំពារសង្គម ដើម្បីកាត់បន្ថយវិសមភាព និងដើម្បីធ្វើឱ្យប្រាកដថា សិទ្ធិរបស់បុគ្គល និងក្រុមដែលទទួលរងនូវគុណវិបត្តិ និងត្រូវគេទុកចោល មិនទទួលរងផលប៉ះពាល់ដោយអសមាមាត្រនោះទេ។

55. ការកាត់មូលនិធិសេវាសង្គម ដែលប៉ះពាល់ខ្លាំងទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយមានរួមទាំងការកើនឡើងនូវបន្ទុកចំពោះស្ត្រីលើការងារថែទាំផងនោះ គួរតែជាវិធានការជម្រើសចុងក្រោយបំផុត ដែលប្រកាន់យក លុះត្រាតែបន្ទាប់ពីមានការពិចារណាម៉ត់ចត់ ទៅលើជម្រើសគោលនយោបាយផ្សេងៗទៀតរួចហើយ ដោយរួមបញ្ចូលទាំង ជម្រើសផ្សេងទៀតក្នុងការផ្តល់ហិរញ្ញប្បទាន។ សេវានានាដែលសំខាន់ចាំបាច់ ដើម្បីឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានសិទ្ធិរបស់ខ្លួន គួរតែមានថវិកាកំណត់នៅក្នុងថវិកាជាតិ និងថវិកាមូលដ្ឋាន។

### គ. រដ្ឋគួរធានាថា សម្ភារៈបរិក្ខារ ទំនិញ និងសេវា ដែលត្រូវការសម្រាប់ការទទួលបានសិទ្ធិមនុស្ស បង្កលក្ខណៈងាយស្រួល អាចរកបាន អាចសម្របតាមស្ថានភាព មានតម្លៃអាចលៃលកបាន និងមានគុណភាពល្អ

56. រដ្ឋមានកាតព្វកិច្ចទាក់ទងទៅនឹងការផ្តល់សម្ភារៈបរិក្ខារ ទំនិញ និងសេវាកម្មដែលជាតម្រូវការសម្រាប់ការទទួលបានសិទ្ធិមនុស្ស។ សូម្បីតែនៅកន្លែងដែលសម្ភារៈបរិក្ខារ ទំនិញ និងសេវាទាំងឡាយ ត្រូវបានផ្តល់ដោយមានការចូលពាក់ព័ន្ធពីវិស័យឯកជន ឬអង្គភាពសង្គមស៊ីវិលក៏ដោយ ក៏រដ្ឋត្រូវទទួលខុសត្រូវក្នុងការធានាអំពីគុណភាពតម្លៃដែលអាចលៃលកបាន និងសេវាគ្របដណ្តប់ ព្រមទាំងមានកាតព្វកិច្ចក្នុងការការពារបុគ្គលប្រឆាំងនឹងការរំលោភបំពានដែលបង្កឡើងដោយអ្នកផ្តល់សេវាឯកជនដែរ។

57. រដ្ឋគួរដកចេញនូវរនាំងឧបសគ្គនានា ដើម្បីធានាឱ្យមានការទទួលបានគ្រប់គ្រាន់ និងដោយគ្មានភាពរើសអើងចំពោះសម្ភារៈបរិក្ខារ ទំនិញ និងសេវានានា សម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ សេវាសំខាន់ចាំបាច់ ក្នុងការសម្រេចបាននូវសិទ្ធិមនុស្ស ក៏ដូចជាការថែទាំសុខភាពនិងការអប់រំ ត្រូវតែបង្កលក្ខណៈងាយស្រួលផ្នែកហិរញ្ញវត្ថុដល់សហគមន៍កំពុងរស់ក្នុងភាពក្រីក្រ និងស្ថិតនៅទីតាំងដែលអាចទៅដល់ដោយសុវត្ថិភាព។ ព័ត៌មានអំពីសេវាទាំងនេះត្រូវតែបង្កលក្ខណៈងាយស្រួលផងដែរ។

58. រដ្ឋគួរធានាឱ្យបាននូវតម្លៃដែលអាចលៃលកបានទៅលើសម្ភារៈបរិក្ខារ ទំនិញ និងសេវានានា ដែលមានភាពទាក់ទងទៅនឹងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ គ្មាននរណាម្នាក់គួរត្រូវបានគេបដិសេធសិទ្ធិក្នុងការទទួលបានសេវាសំខាន់ចាំបាច់ទាំងនេះ ដោយសារតែពុំមានលទ្ធភាពនៅក្នុងការបង់ប្រាក់នោះឡើយ។ នៅក្នុងករណីមួយចំនួន រដ្ឋត្រូវតែផ្តល់សេវាដោយមិនគិតកម្រៃ ឧទាហរណ៍ ការអប់រំកម្រិតបឋមសិក្សាត្រូវតែជាកាតព្វកិច្ច និងមិនគិតកម្រៃ ទាំងការចំណាយដោយផ្ទាល់និងការចំណាយដោយប្រយោល។

59. រដ្ឋគួរធានាអំពីភាពអាចទទួលយកបាន និងភាពសម្របតាមស្ថានភាព នៃសម្ភារៈបរិក្ខារ ទំនិញ និងសេវាកម្មទាក់ទងទៅនឹងតម្រូវការជាក់លាក់របស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយពិចារណាទៅលើភាពខុសប្លែកគ្នាផ្នែក

វប្បធម៌ ឧបសគ្គផ្នែកភាសា តម្រូវការយេនឌ័រជាក់លាក់ និងការរើសអើង។ ក្នុងករណីមួយចំនួន រដ្ឋត្រូវធានាថា ជំនួយត្រូវបានរៀបចំឱ្យសមស្របទៅនឹងតម្រូវការរបស់ក្រុមមនុស្សជាក់លាក់។

60. រដ្ឋគួរធានាថាសម្ភារៈបរិក្ខារ ទំនិញ និងសេវាកម្មដែលប្រើប្រាស់ដោយមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានគុណភាពខ្ពស់បំផុត ដោយរួមទាំង តាមរយៈការតាមដានទៅលើគុណភាពនៃអ្នកផ្តល់សេវាសាធារណៈ និងឯកជន។ អ្នកផ្តល់សេវាត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ និងដឹងអំពីតម្រូវការជាក់លាក់របស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## ឃ. រដ្ឋគួរធានាឱ្យគោលនយោបាយមានភាពស៊ីសង្វាក់គ្នា

61. រដ្ឋគួរពិចារណាទៅលើកាតព្វកិច្ចសិទ្ធិមនុស្សជាលក្ខណៈអន្តរជាតិ នៅពេលរៀបចំបង្កើត និងអនុវត្តរាល់គោលនយោបាយ ដោយរួមមានទាំង គោលនយោបាយពាណិជ្ជកម្មអន្តរជាតិ គោលនយោបាយពន្ធគយ គោលនយោបាយ សារពើពន្ធប្រចាំឆ្នាំ គោលនយោបាយរូបិយវត្ថុ គោលនយោបាយបរិស្ថាន និងគោលនយោបាយវិនិយោគ។ ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិ ចំពោះការកាត់បន្ថយភាពក្រីក្រ មិនគួរចាត់ទុកថា ជាអ្វីដែលនៅដាច់ដោយឡែកពីគោលនយោបាយ និងការសម្រេចនៅថ្នាក់ជាតិ និងអន្តរជាតិ ដែលកត្តាមួយចំនួនអាចបណ្តាលឱ្យមានលក្ខខណ្ឌបង្កើត រក្សា ឬបង្កើនភាពក្រីក្រ ទាំងនៅក្នុងប្រទេស ឬនៅក្រៅដែនដី។ មុនពេលអនុម័តកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬអនុវត្តវិធានការគោលនយោបាយណាមួយ រដ្ឋគួរធ្វើការប៉ាន់ប្រមាណថាតើកិច្ចព្រមព្រៀងឬវិធានការនោះ ស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនឬទេ។

## V. សិទ្ធិជាក់លាក់

62. សិទ្ធិមនុស្សទាំងអស់មាន សិទ្ធពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ អនុវត្តទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ហើយពួកគេគួរតែទទួលបានសិទ្ធិមនុស្សទាំងអស់។ ការយកចិត្តទុកដាក់ត្រូវតែមាន ចំពោះសិទ្ធិជាក់លាក់មួយចំនួនដូចខាងក្រោមនេះ ជាសិទ្ធដែលមនុស្សកំពុងរស់ក្នុងភាពក្រីក្រទទួលបានដោយមានដែនកំណត់ និងរឹតត្បឹត ហើយជាអ្វីដែលគោលនយោបាយរបស់រដ្ឋជារឿយៗ មានភាពមិនគ្រប់គ្រាន់ និងជាការរារាំងទៅវិញ។ មានការផ្តល់នូវមគ្គុទេសន៍អំពីរបៀបគោរព ការពារ និងបំពេញសិទ្ធិទាំងនេះសម្រាប់មនុស្សរស់ក្នុងភាពក្រីក្រ។ អត្ថបទនេះមិនមែនជាសេចក្តីសង្ខេប ឬជាសេចក្តីថ្លែងណាមួយអំពីខ្លឹមសារស្នូលនៃសិទ្ធិនីមួយៗនោះទេ វាគួរតែមានការបកស្រាយ និងអនុវត្តឱ្យស្របនឹងកាតព្វកិច្ចជាធរមានបច្ចុប្បន្ន ក្រោមច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងគោរពតាមសេចក្តីពន្យល់រួម ឬអនុសាសន៍ទូទៅនៃយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

## ក. សិទ្ធិរស់រានមានជីវិតនិងបូរណភាពរាងកាយ

63. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ ប្រឈមនឹងហានិភ័យលក្ខណៈស្ថាប័ននិងបុគ្គល ចំពោះអំពើហិង្សា និងការគំរាមកំហែងនានាទៅលើបូរណភាពរាងកាយ ពីសំណាក់ភ្នាក់ងាររដ្ឋ និងតួអង្គឯកជន ដែលបណ្តាលឱ្យពួកគេរស់នៅក្នុងភាពភ័យខ្លាច និងអសន្តិសុខជាប្រចាំ។ ការប្រឈមមុខនឹងភាពងាយរងគ្រោះ ចំពោះអំពើហិង្សាដែលនៅតែបន្តកើតឡើងនេះ បានប៉ះពាល់ទៅដល់សុខភាពផ្លូវកាយនិងផ្លូវចិត្ត ព្រមទាំងធ្វើឱ្យខូចខាតដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសមត្ថភាពក្នុងការងើបឱ្យផុតពីភាពក្រីក្រ។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដែលមានឯករាជ្យភាពផ្នែកសេដ្ឋកិច្ចតិចតួចឬគ្មានទាល់តែសោះ មានលទ្ធភាពតិចតួចណាស់ក្នុងការស្វែងរកការគាំពារ និងការរស់នៅ

ដោយសុវត្ថិភាព។ ជារឿយៗ ភ្នាក់ងារអនុវត្តច្បាប់ ប្រមូលកត់ត្រាព័ត៌មានអំពីពួកគេ និងផ្តោតគោលដៅដោយចេតនាទៅលើអ្នករស់នៅក្នុងភាពក្រីក្រ។ ស្ត្រីនិងក្មេងស្រីកំពុងរស់ក្នុងភាពក្រីក្រ ទទួលរងអំពើហិង្សាផ្អែកលើយេនឌ័រ ដែលរួមមានទាំង អំពើហិង្សាក្នុងគ្រួសារ ការបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទ និងការអនុវត្តបែបប្រពៃណីដែលបង្កគ្រោះថ្នាក់ និងបញ្ហាប្រឈមដទៃទៀត។ ជាងនេះទៀត ភាពក្រីក្រ គឺជាបុព្វហេតុនៃការស្លាប់ដែលអាចទប់ស្កាត់បាន បញ្ហាសុខភាព អត្រាមរណៈខ្ពស់ និងអាយុកាលសង្ឃឹមរស់ទាប មិនមែនត្រឹមតែដោយសារតែការប្រឈមធ្ងន់ធ្ងរទៅនឹងអំពើហិង្សានោះទេ ប៉ុន្តែថែមទាំងប្រឈមនឹងការដកហូតសម្ភារៈ និងផលវិបាកនានា ដូចជាកង្វះម្ហូបអាហារ ទឹកដែលមានសុវត្ថិភាព និងអនាម័យ។

64. រដ្ឋគួរៈ

ក. ចាត់វិធានការពិសេសនានាដើម្បីធានាថា សិទ្ធិរស់រានមានជីវិត និងបូរណភាពរាងកាយរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ត្រូវបានគោរព ការពារ និងបំពេញ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា ដោយរួមមានទាំង តាមរយៈការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ការត្រួតពិនិត្យឡើងវិញទៅលើដំណើរការនីតិវិធីរបស់ប៉ូលិស និងការបង្កើតនូវប្រព័ន្ធគណនេយ្យភាពច្បាស់លាស់ដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាជនដែលទទួលរងគុណវិបត្តិបំផុត។

ខ. រៀបចំបង្កើតយុទ្ធសាស្ត្រ និងប្រព័ន្ធជាក់លាក់ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រដែលប្រព្រឹត្តទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលទាំងការផ្តល់ជម្រកសម្រាប់ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារផង។

គ. ចាត់រាល់វិធានការដែលអាចធ្វើទៅបានទាំងអស់ ឱ្យបានដល់កម្រិតអតិបរមានៃធនធានដែលអាចរកបាន ដើម្បីធានាថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានយ៉ាងហោចណាស់ ចំណីអាហារចាំបាច់ក្នុងកម្រិតអប្បបរមាដែលមានជីវជាតិគ្រប់គ្រាន់និងមានសុវត្ថិភាព ជម្រក លំនៅឋាន និងអនាម័យជាមូលដ្ឋាន ព្រមទាំងការផ្គត់ផ្គង់ទឹកផឹកមានសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ ដើម្បីបង្ការជំងឺ និងផលវិបាកដ៏គ្រោះថ្នាក់ពីការដកហូតសម្ភារៈទាំងអស់នោះ រួមបញ្ចូលទាំង កង្វះអាហារូបត្ថម្ភ ជំងឺឆ្លង និងអត្រាមរណៈមាតានិងទារក។

## ខ. សិទ្ធិទទួលបានសេរីភាព និងសន្តិសុខបុគ្គល

65. កត្តាសង្គមនិងកត្តារចនាសម្ព័ន្ធផ្សេងៗ រួមមានការរើសអើង បានបណ្តាលឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្រចូលពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយភាពញឹកញាប់ក្នុងកម្រិតខ្ពស់យ៉ាងអសមាមាត្រ។ ពួកគេក៏ជួបប្រទះឧបសគ្គជាច្រើន ក្នុងការចាកចេញពីប្រព័ន្ធនេះផងដែរ។ ជាលទ្ធផល ចំនួនមនុស្សដែលក្រីក្របំផុតនិងដែលត្រូវបានគេផាត់ចេញបំផុតក្នុងអត្រាខ្ពស់ដោយអសមាមាត្រ ត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ឬដាក់ក្នុងពន្ធនាគារ។ ពួកគេជាច្រើនទទួលរងនូវការឃុំខ្លួនបណ្តោះអាសន្ន រយៈពេលវែងដោយពុំទទួលបានដំណើរការនីតិវិធីត្រឹមត្រូវនៃការសុំនៅក្រៅឃុំ ឬការត្រួតពិនិត្យឡើងវិញលើករណីរបស់ពួកគេឡើយ។ ជារឿយៗ ពួកគេពុំមានលទ្ធភាពរកតំណាងផ្លូវច្បាប់សមស្របនោះទេ ហើយពួកគេច្រើនតែត្រូវទទួលការផ្តន្ទាទោស។ អំឡុងពេលជាប់ឃុំឃាំង ជាញឹកញាប់ពួកគេគ្មានលទ្ធភាពរកមធ្យោបាយដើម្បីតវ៉ាជំទាស់នឹងការបំពានសិទ្ធិរបស់ពួកគេឡើយ ដូចជាលក្ខខណ្ឌគ្មានសុវត្ថិភាព ឬគ្មានអនាម័យ ការរំលោភបំពាន ឬការពន្យារពេលដ៏វែង។ ការដាក់ពិន័យទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានផលប៉ះពាល់ដោយអសមាមាត្រទៅលើពួកគេ ដែលវាធ្វើឱ្យស្ថានភាពរបស់ពួកគេកាន់តែអាក្រក់

ឡើង និងធ្វើឱ្យវដ្តដ៏អាក្រក់នៃភាពក្រីក្រនៅតែបន្តកើតមានឡើង។ ដោយឡែក មនុស្សគ្មានផ្ទះសម្បែង ជាញឹកញយ តែងរងនូវការរឹតត្បិតទៅលើសេរីភាពក្នុងការបម្លាស់ទី និងត្រូវបានរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ក្នុងការប្រើប្រាស់លម្ហសាធារណៈ។

66. រដ្ឋគួរ៖

ក. ប៉ាន់ប្រមាណនិងដោះស្រាយចំពោះផលប៉ះពាល់ដោយអសមាមាត្រ ពីការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ និងដំណើរការនីតិវិធីដាក់ពន្ធនាគារទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

ខ. តាមដែលអាចធ្វើទៅបានជាអតិប្បរមា ត្រូវធានាថា ដំណើរការសុំនៅក្រៅឃុំ គួរពិចារណាទៅលើកាលៈទេសៈសេដ្ឋកិច្ចនិងសង្គមរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

គ. លុបចោលឬធ្វើវិសោធនកម្មច្បាប់ទាំងឡាយណា ដែលចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើសកម្មភាពរក្សាជីវិតនៅទីសាធារណៈ ដូចជា ការដេក ការសុំទាន ការហូបចុក ឬសកម្មភាពអនាម័យផ្ទាល់ខ្លួនជាដើម។

ឃ. ត្រួតពិនិត្យឡើងវិញលើនីតិវិធីដាក់ទណ្ឌកម្ម ដែលតម្រូវឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្របង់ប្រាក់ពិន័យដោយអសមាមាត្រ ជាពិសេសទាក់ទងនឹងអ្នកដែលធ្វើការសុំទាន ប្រើប្រាស់លម្ហសាធារណៈ និងគែបន្លំផ្នែកសុខុមាលភាព ព្រមទាំងពិចារណាលើការលុបបំបាត់ការកាត់ទោសឱ្យជាប់ពន្ធនាគារចំពោះការមិនបង់ប្រាក់ពិន័យ សម្រាប់មនុស្សដែលពុំមានលទ្ធភាពបង់។

## គ. សិទ្ធិទទួលបានការគាំពារដោយស្មើភាពនៅចំពោះមុខច្បាប់ ការទទួលបានយុត្តិធម៌ និងសំណងដំណោះស្រាយមានប្រសិទ្ធភាព

67. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ មិនមានលទ្ធភាពក្នុងការទទួលបានយុត្តិធម៌ ឬស្វែងរកសំណងសម្រាប់សកម្មភាពឬការខូចខាតណាមួយ ដែលប៉ះពាល់ធ្ងន់ធ្ងរទៅលើពួកគេទេ។ ពួកគេជួបប្រទះឧបសគ្គនានាជាច្រើន រាប់ចាប់តាំងពីការមិនមានលទ្ធភាពក្នុងការចុះបញ្ជីបណ្តឹងបឋមឱ្យបានជោគជ័យ ដោយសារត្រូវការចំណាយប្រាក់ ឬមិនយល់ដឹងពីផ្លូវច្បាប់ រហូតដល់ការមិនអាចអនុវត្តបាននូវសេចក្តីសម្រេចរបស់តុលាការដែលសម្រេចឱ្យពួកគេឈ្នះក្តី។ អតុល្យភាពអំណាច និងកង្វះយន្តការបណ្តឹងឯករាជ្យ បញ្ហានៃការទៅប្រើប្រាស់និងប្រសិទ្ធភាពនៃយន្តការដោះស្រាយបណ្តឹង ជារឿយៗ រារាំងពួកគេពីការប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចចិត្តផ្នែករដ្ឋបាលដែលប៉ះពាល់ធ្ងន់ធ្ងរទៅដល់ពួកគេ។ បើគ្មានការទទួលបានយុត្តិធម៌ប្រកបដោយប្រសិទ្ធភាពទេនោះ ពួកគេពុំអាចស្វែងរកនិងទទួលបានសំណងដំណោះស្រាយសម្រាប់ការបំពានច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដែលវាធ្វើឱ្យកាន់តែអាក្រក់ឡើងដល់ភាពងាយរងគ្រោះ សន្តិសុខ និងភាពឯកា ព្រមទាំងធ្វើឱ្យភាពក្រីក្ររបស់ពួកគេនៅតែបន្តកើតមានឡើង។

68. រដ្ឋគួរ៖

ក. បង្កើតនីតិវិធីដែលមានប្រសិទ្ធភាព មានតម្លៃអាចលៃលកបាន និងបង្កលក្ខណៈងាយស្រួល ដោយរួមបញ្ចូលទាំងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ស្របតាមស្តង់ដារសិទ្ធិមនុស្ស ដើម្បីគាំទ្រដល់មនុស្សកំពុងរស់

ក្នុងភាពក្រីក្រក្នុងការស្វែងរកយុត្តិធម៌ ដោយពិចារណាទៅលើឧបសគ្គជាក់លាក់នានា ដែលពួកគេជួបប្រទះក្នុងការទទួលបានយុត្តិធម៌។

ខ. សម្រាប់ករណីព្រហ្មទណ្ឌនិងករណីរដ្ឋប្បវេណីដែលប៉ះពាល់ដល់សិទ្ធិរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ រដ្ឋគួរផ្តល់ប្រព័ន្ធជំនួយផ្លូវច្បាប់ដែលមានគុណភាពខ្ពស់ និងពង្រីកបន្ថែមសេវាផ្លូវច្បាប់សម្រាប់អ្នកដែលពុំអាចមានលទ្ធភាពបង់ថ្លៃចំណាយសម្រាប់តំណាងផ្លូវច្បាប់។

គ. ដាក់ឱ្យអនុវត្តនូវវិធានការនានាដើម្បីធានាថា កម្រៃសេវាផ្លូវច្បាប់និងប្រាក់ប្រដាប់ក្តី (ដូចជាសម្រាប់ការដាក់បណ្តឹងជាដើម) ត្រូវបានលើកលែងសម្រាប់មនុស្សដែលមិនអាចលៃលកចំណាយបាន។

ឃ. ធានាថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានសំណងដំណោះស្រាយ នៅក្នុងករណីនៃការរើសអើង ដោយឈរលើមូលហេតុស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ពួកគេ។

ង. វិនិយោគលើការបណ្តុះបណ្តាលចៅក្រម មេធាវី ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ក្នុងការបំពេញតម្រូវការជាក់លាក់របស់ក្រុមផ្សេងៗគ្នាដែលកំពុងរស់ក្នុងភាពក្រីក្រ និងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការបំពេញតួនាទី ដោយគ្មានការរើសអើង។

ច. បង្កើតយន្តការបណ្តឹងដែលមានភាពឯករាជ្យ មានធនធានគ្រប់គ្រាន់ និងគិតគូដល់តម្រូវការយេនឌ័រ នៅក្នុងគោលនយោបាយសាធារណៈ ដើម្បីធានាឱ្យមានការតាមដានឃ្លាំមើលនិងដើម្បីបង្កលក្ខណៈឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្រ អាចដាក់បណ្តឹងអំពីការបំពានអំណាចនិងសមត្ថកិច្ច អំពើពុករលួយ និងការរើសអើង។

ឆ. បង្កើតយន្តការបណ្តឹង ប្រឹក្សាយោបល់ និងរាយការណ៍ ដែលគិតគូដល់ស្ថានភាពកុមារ ដែលបង្កលក្ខណៈងាយស្រួលដល់ការប្រើប្រាស់របស់កុមារកំពុងរស់ក្នុងភាពក្រីក្រ និងអនុវត្តយុទ្ធនាការផ្តល់ព័ត៌មាន ដើម្បីធានាឱ្យមានការដឹងឮអំពីយន្តការទាំងអស់នោះ។

ជ. បង្កើនភាពអាចរកបាននូវព័ត៌មានផ្លូវច្បាប់ទៅដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយរាប់បញ្ចូលទាំងតាមរយៈការផ្សព្វផ្សាយ តាមមធ្យោបាយផ្សេងៗជាច្រើនទៀតដែលអាចសម្របតាមស្ថានភាព និងការយល់ដឹងអំពីវប្បធម៌ផ្សេងគ្នា។

ឈ. បង្កើតការផ្តល់សំណងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព (រួមបញ្ចូលទាំង ការទទួលស្គាល់តាមច្បាប់ជាតិ និងការដាក់បណ្តឹងតវ៉ាតាមផ្លូវតុលាការ) សម្រាប់សិទ្ធិទាំងអស់ដែលមានចែងនៅក្នុងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលរួមបញ្ចូលទាំងសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌។

### ឃ. សិទ្ធិទទួលបានការទទួលស្គាល់ជាបុគ្គលនៅចំពោះមុខច្បាប់

69. ឧបសគ្គជាច្រើនក្នុងផ្នែកច្បាប់ សេដ្ឋកិច្ច នីតិវិធី ការអនុវត្តជាក់ស្តែង និងវប្បធម៌ បានរារាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រពីការចុះបញ្ជីកំណើត និងការទទួលបានឯកសារអត្តសញ្ញាណតាមផ្លូវច្បាប់។ ប្រជាជនមួយចំនួនរស់នៅដោយគ្មានសិទ្ធចូលទៅកាន់មណ្ឌលចុះបញ្ជីទេ អ្នកផ្សេងទៀតមិនអាចមានលទ្ធភាពក្នុងការបង់កម្រៃដោយផ្ទាល់និងដោយប្រយោលនោះទេ ហើយក៏មានអ្នកដទៃទៀតត្រូវបានគេមិនផ្តល់ឯកសារអត្តសញ្ញាណតាមផ្លូវច្បាប់

ដោយសារតែការរើសអើង។ បើគ្មានសំបុត្រកំណើត និងឯកសារពាក់ព័ន្ធទេនោះ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ មិនអាចមានលទ្ធភាពក្នុងការសម្រេចបាននូវសិទ្ធិជាច្រើនរបស់ពួកគេទេ ដោយរួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានសន្តិសុខសង្គម អប់រំ សុខភាព និងការធានាបានយុត្តិធម៌។ កង្វះការចុះបញ្ជីកំណើត ក៏បង្កើនហានិភ័យនៃភាពគ្មានរដ្ឋ ពីព្រោះបុគ្គលទាំងអស់នេះអាចពុំមានលទ្ធភាពក្នុងការបង្កើតសញ្ជាតិរបស់ខ្លួនឯង នៅគ្រាក្រោយមកនៅក្នុងជីវិតរបស់ពួកគេឡើយ។

70. រដ្ឋគួរះ

ក. បង្កើតកិច្ចប្រឹងប្រែងដែលចាំបាច់ទាំងឡាយ ដើម្បីចុះបញ្ជីកំណើតកុមារទាំងអស់ក្រោយកំណើតភ្លាម។

ខ. អនុវត្តការជំរុញឱ្យមានការចុះបញ្ជី រួមបញ្ចូលទាំង យុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់មនុស្សពេញវ័យ និងកុមារដែលមិនទាន់ចុះបញ្ជីកំណើត ព្រមទាំងធានាការចេញឯកសារអត្តសញ្ញាណសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រតាមការចាំបាច់ ដើម្បីឱ្យមានការទទួលបានសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងការទទួលបានសិទ្ធិទាំងអស់។

គ. បែងចែកផ្តល់ធនធានដែលចាំបាច់សម្រាប់ការបង្កើតប្រព័ន្ធចុះបញ្ជីដែលបង្កលក្ខណៈងាយស្រួលនិងសមស្របសម្រាប់មនុស្សរស់ក្នុងភាពក្រីក្រ។ ប្រព័ន្ធទាំងអស់នេះ គួរតែមិនគិតកម្រៃ សាមញ្ញ លឿន និងប្រតិបត្តិការដោយគ្មានការរើសអើង។

ឃ. កំណត់ឱ្យឃើញនិងដកចេញនូវរបាំងឧបសគ្គនានាដែលរារាំងការទទួលបានការចុះបញ្ជីកំណើតដល់ក្រុមទទួលរងគុណវិបត្តិ ដែលមានហានិភ័យចំពោះភាពក្រីក្រ ដូចជាជនស្វែងរកសិទ្ធិជ្រកកោន បុគ្គលគ្មានសញ្ជាតិ (គ្មានរដ្ឋ) ជនមានពិការភាព និងជនចំណាកស្រុកដែលគ្មានឯកសារគ្រប់គ្រាន់។

ង. នៅទីណាដែលមិនមានផ្តល់ការចុះបញ្ជីកំណើតឬឯកសារអត្តសញ្ញាណដោយសមហេតុផលនោះ ត្រូវធានាថាតុលាការពង្រីកសមត្ថកិច្ចផ្លូវច្បាប់លើបញ្ហានេះ ដោយគ្មានការរើសអើង។

### ង. សិទ្ធិឯកជនភាព និងការគាំពារលំនៅឋាន និងគ្រួសារ

71. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទំនងជាទទួលរងការវាយប្រហារជាច្រើនទៅលើឯកជនភាព និងកិត្តិយសពីសំណាក់តួអង្គរដ្ឋនិងតួអង្គមិនមែនរដ្ឋ។ ការប៉ះពាល់លើជីវិតឯកជននេះ អាចបណ្តាលមកពីលក្ខខណ្ឌនៃលំនៅឋានរស់នៅមានភាពចង្អៀតកកកុញ ឬដោយសារតែអន្តរាគមន៍ជ្រុលពីសេវាអនុវត្តច្បាប់ ឬសេវាសង្គមផ្សេងទៀត។ ឧទាហរណ៍ ក្មេងដែលចេញមកពីគ្រួសារកំពុងរស់ក្នុងភាពក្រីក្រ មានហានិភ័យខ្ពស់ខ្លាំងនឹងការដែលអាជ្ញាធរដកយកគាត់ចេញពីគ្រួសារនិងយកទៅដាក់នៅក្រោមការថែទាំរបស់មជ្ឈមណ្ឌល។

72. រដ្ឋគួរះ

ក. កែប្រែក្របខណ្ឌច្បាប់ និងក្របខណ្ឌរដ្ឋបាល ដើម្បីការពារមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ពីការជ្រៀតជ្រែកចូលក្នុងជីវិតឯកជនរបស់ពួកគេដោយអាជ្ញាធរក្នុងសភាពមិនសមស្រប។ គោលនយោបាយតាមឃ្លាំមើល លក្ខខណ្ឌកំណត់ទាក់ទងនឹងសុខុមាលភាព និងលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលផ្សេងទៀត ត្រូវតែត្រួតពិនិត្យឡើងវិញដើម្បីធានា

ថា មិនមានការដាក់បន្ទុកដោយអសមាមាត្រ ទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ឬជ្រៀតចូលទៅក្នុងឯកជនភាពរបស់ពួកគេ។

ខ. ធានាថា ភាពក្រីក្រខាងផ្នែកហិរញ្ញវត្ថុនិងសម្ភារៈ មិនត្រូវប្រើជាហេតុផលតែមួយគត់ក្នុងការដកហូតកុមារណាម្នាក់ចេញពីការថែទាំរបស់ឪពុកម្តាយ ឬរារាំងពួកគេពីការធ្វើសមាហរណកម្មនោះទេ។ ស្របតាមកាតព្វកិច្ចក្នុងការការពារឧត្តមប្រយោជន៍របស់កុមារនៅក្នុងដំណើរនីតិវិធីគាំពារកុមារ កិច្ចខិតខំប្រឹងប្រែងគួរផ្តោតជាសំខាន់សំដៅទៅបង្កលក្ខណៈឱ្យកុមារបានបន្តរស់នៅឬវិលត្រឡប់ទៅរស់នៅក្រោមការថែទាំរបស់ឪពុកម្តាយវិញ ដោយរួមបញ្ចូលទាំងតាមរយៈការលុបបំបាត់ការដកហូតសម្ភារៈពីគ្រួសារផង។

គ. ជាចំណែកមួយនៃគោលនយោបាយសុខុមាលភាពកុមារនិងគាំពារកុមារគ្រប់ជ្រុងជ្រោយ រៀបចំបង្កើតនិងអនុវត្តកម្មវិធីគាំទ្រគ្រួសារដែលមានលក្ខណៈសមស្រប មានធនធានគ្រប់គ្រាន់ និងមានការយល់ដឹងផ្នែកវប្បធម៌ ដើម្បីបង្កលក្ខណៈងាយស្រួលដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## ច. សិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ

73. រដ្ឋមានកាតព្វកិច្ចនៅក្នុងការកែលម្អតាមភាពរីកចម្រើនជាក់ស្តែង នូវលក្ខខណ្ឌរស់នៅរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ ខណៈដែលសិទ្ធិក្នុងការទទួលបានស្តង់ដាររស់នៅសមរម្យ រួមបញ្ចូលសិទ្ធិជាក់លាក់មួយចំនួន មានសិទ្ធិខ្លះហាក់ដូចជានៅមានកម្រិតទាបណាស់ ហើយដែលជាក់ស្តែងវាគឺជាសិទ្ធិដ៏សំខាន់បំផុតគ្របដណ្តប់លើធាតុផ្សំសំខាន់ចាំបាច់សម្រាប់ការរស់រានមានជីវិត សុខភាព ការអភិវឌ្ឍរាងកាយ និងបញ្ញាស្មារតីរបស់មនុស្ស។ កង្វះស្តង់ដាររស់នៅសមរម្យ គឺទាក់ទងនឹងមធ្យោបាយដែលមានលក្ខណៈកំហិតឬអសន្តិសុខសម្រាប់ជីវភាពរស់នៅ។ ជារឿយៗ កង្វះប្រាក់ចំណូលនិងតម្លៃសម្ភារៈដែលជាតម្រូវការមូលដ្ឋានចាំបាច់ រួមគ្នាបង្កើតបានជាឧបសគ្គចម្បងមួយនៅក្នុងតំបន់ទីក្រុង។ សហគមន៍ជនបទ ជាធម្មតា ពឹងផ្អែកខ្លាំងលើការប្រើប្រាស់ដោយសុវត្ថិភាពនិងសមធម៌នូវធនធានដីធ្លី ជលផល និងព្រៃឈើ ដែលជាប្រភពស្បៀងអាហារនិងទីជម្រក ហើយការប្រើប្រាស់នេះគឺជាមូលដ្ឋាននៃការអនុវត្តផ្នែកសង្គម វប្បធម៌ និងសាសនា ព្រមទាំងជាកត្តាស្នូលសម្រាប់កំណើនសេដ្ឋកិច្ច។ មនុស្សជាច្រើន ដោយរួមបញ្ចូលទាំងស្ត្រីជនជាតិដើមភាគតិច និងកសិករខ្នាតតូចផងនោះ ខ្វះសិទ្ធិគ្រប់គ្រងដែលអាចអនុវត្តបានតាមច្បាប់ និងដោយនិរន្តរភាពលើការប្រើប្រាស់ធនធានទាំងនេះ។

74. រដ្ឋគួរ

ក. ដកចេញនូវឧបសគ្គផ្នែកសេដ្ឋកិច្ច សង្គម និងរដ្ឋបាល ដែលរារាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ពីការចូលរួមក្នុងសកម្មភាពជីវភាពផលិតកម្ម និងដាក់បញ្ចូលនូវមធ្យោបាយកសាងទ្រព្យធន ជំនាញ និងសមត្ថភាពផលិតកម្ម។

ខ. វិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ ដើម្បីកែលម្អការទទួលបានសេវាជាមូលដ្ឋានដែលចាំបាច់សម្រាប់ស្តង់ដាររស់នៅសមរម្យ និងបង្កើតជម្រើសថាមពលនិងបច្ចេកវិទ្យាកាន់តែប្រសើរ សម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

គ. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានសមរម្យនូវប្រភពធនធានប្រើប្រាស់ មានដូចជា ដីធ្លី ជលផល និងព្រៃឈើ ព្រមទាំង ទឹកគ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មចិញ្ចឹមជីវិត ដែលក្នុងចំណោមវិធានការនានាគឺតាមរយៈការ

ចាត់វិធានការដាក់លាក់តាមផ្លូវច្បាប់ រដ្ឋបាល និងគោលនយោបាយ ដើម្បីលើកកម្ពស់និងធានាឱ្យមានការគ្រប់គ្រងធនធានផលិតកម្មប្រកបដោយនិរន្តរភាព។

ឃ. ធានាថាជនជាតិដើមភាគតិច មានសិទ្ធិទទួលបានដីធ្លី ដែនដី និងធនធាននានា ដែលពួកគេធ្វើជាម្ចាស់ កាន់កាប់ ឬប្រើប្រាស់ និងទទួលបានតាមលក្ខណៈប្រពៃណី។

ង. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជាពិសេសស្ត្រី ទទួលបានសេវាហិរញ្ញវត្ថុចាំបាច់ រួមបញ្ចូលទាំងកម្ចីពីធនាគារ ការបង់រំលស់ និងទម្រង់ផ្សេងទៀតនៃឥណទាន ព្រមទាំងមធ្យោបាយសន្សំដែលមានសុវត្ថិភាពនិងមានតម្លៃអាចលៃលកបាន។

ច. ធានាថា គោលនយោបាយដោះស្រាយទៅលើគ្រប់វិស័យនៃសិទ្ធិក្នុងការទទួលបានស្តង់ដាជីវភាពរស់នៅសមរម្យ ដូចជាស្បៀងអាហារ ទឹក អនាម័យ និងលំនៅឋាន មានលក្ខណៈគ្រប់ជ្រុងជ្រោយនិងសមាហរណកម្ម។

**ឆ. សិទ្ធិទទួលបានចំណីអាហារនិងអាហារូបត្ថម្ភគ្រប់គ្រាន់**

75. ស្បៀងអាហារគ្រប់គ្រាន់ មានភាពសំខាន់ចាំបាច់សម្រាប់សុខភាព ការរស់រានមានជីវិត និងការអភិវឌ្ឍរាងកាយនិងបញ្ញាស្មារតី ព្រមទាំងជាបុរេលក្ខខណ្ឌសម្រាប់សមាហរណកម្មសង្គម ភាពសុខដុមក្នុងសង្គម និងជីវភាពសហគមន៍ប្រកបដោយសន្តិភាព។ កង្វះអធិបតេយ្យភាពស្បៀងអាហារ ជាការធ្វើឱ្យចុះខ្សោយដល់ស្វ័យភាព និងសេចក្តីថ្លៃថ្នូរ។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ មានការទទួលបានដ៏កំហិតនូវស្បៀងអាហារដែលមានលក្ខណៈគ្រប់គ្រាន់និងអាចលៃលកទិញបាន ឬធនធានដែលពួកគេត្រូវការសម្រាប់ការផលិតឬដើម្បីទទួលបានស្បៀងអាហារទាំងអស់នោះ។ សូម្បីតែនៅទីកន្លែងដែលអាចរកស្បៀងអាហារគ្រប់គ្រាន់បានក៏ដោយ ក៏ជារឿយៗ វាមិនបានទៅដល់ដៃមនុស្សកំពុងរស់ក្នុងភាពក្រីក្រទេ ឧទាហរណ៍ ដោយសារតែតម្លៃ ការបែងចែកមិនសមស្រប ឬការបែងចែកបែបរើសអើង សមត្ថភាពដ៏មានដែនកំណត់របស់ក្រុមដែលគេផាត់ចេញពីសង្គមក្នុងការទទួលបានធនធានផលិតកម្ម កង្វះហេដ្ឋារចនាសម្ព័ន្ធ ឬជម្លោះ។ គុណភាព ឬគុណតម្លៃខាងអាហារូបត្ថម្ភរបស់ស្បៀងអាហារដែលមនុស្សកំពុងរស់ក្នុងភាពក្រីក្រអាចទទួលបានក៏នៅតែជាក្តីបារម្ភចម្បងមួយនៅឡើយ។ លទ្ធផលនៃការរើសអើងលក្ខណៈស្ថាប័ន និងនៅក្នុងគ្រួសារ ឬការអនុវត្តតាមប្រពៃណីនោះ គឺស្ត្រីកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗត្រូវបានគេបដិសេធនូវការទទួលបានស្បៀងអាហារដែលមានលក្ខណៈសមធម៌ ឬមិនត្រូវគេផ្តល់តម្លៃដល់សមត្ថភាពរបស់ពួកគេក្នុងការទិញឬផលិតឡើយ។

76. រដ្ឋគួរ

ក. បង្កើតប្រព័ន្ធផែនទីបង្ហាញទិន្នន័យបំបែកលំអិតច្បាស់លាស់ ដើម្បីកំណត់ឱ្យឃើញនូវក្រុមមនុស្សនិងគ្រួសារដែលមានភាពងាយរងគ្រោះជាពិសេស ចំពោះអសន្តិសុខស្បៀងនិងអសន្តិសុខអាហារូបត្ថម្ភ ព្រមទាំងមូលហេតុនៃភាពងាយរងគ្រោះនោះ ព្រមទាំងចាត់វិធានការកែតម្រូវដែលត្រូវអនុវត្តបន្ទាន់និងតាមភាពរីកចម្រើន ដើម្បីផ្តល់ដល់ពួកគេនូវការទទួលបានស្បៀងអាហារគ្រប់គ្រាន់។

ខ. អនុម័តយុទ្ធសាស្ត្រថ្នាក់ជាតិដើម្បីធានាឱ្យមានសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ទាំងអស់គ្នា ដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស។ ការទទួលបានស្បៀងអាហារគ្រប់គ្រាន់សម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ គួរតែ

ស្របទៅនឹងអាទិភាព និងពិចារណាទៅលើអន្តរព័ន្ធនឹងផ្នែក នៃការទទួលបានធនធានផលិតកម្ម និងរូបិយវត្ថុ ព្រមទាំងអាហារូបត្ថម្ភគ្រប់គ្រាន់។

គ. ដាក់ឱ្យអនុវត្តនូវយន្តការផ្តល់ព័ត៌មានព្រមានទុកជាមុនឱ្យបានគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ឬកាត់បន្ថយការជះឥទ្ធិពលពីគ្រោះមហន្តរាយធម្មជាតិឬគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស ដែលរួមបញ្ចូលទាំងទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ក្នុងតំបន់ដាច់ស្រយាល និងត្រូវគេទុកចោល ព្រមទាំងចាត់វិធានការត្រៀមសម្រាប់គ្រាអាសន្នឱ្យបានសមស្រប។

ឃ. ធានាឱ្យទទួលបានធនធានផលិតកម្មគ្រប់គ្រាន់ ដោយរួមទាំង ដីធ្លី ព្រៃឈើ និងជលផល ដើម្បីឱ្យមនុស្សកំពុងរស់ក្នុងភាពក្រីក្រ អាចផលិតស្បៀងអាហារសម្រាប់ខ្លួនឯងនិងសម្រាប់គ្រួសាររបស់ខ្លួន។

ង. អនុវត្តនូវកម្មវិធីបែងចែកដីធ្លី និងកំណែទម្រង់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅក្នុងតំបន់ដែលមានការប្រមូលផ្តុំដីទុក ដែលវាគំរាមកំហែងដល់ការទទួលបានជីវភាពរស់នៅសម្រាប់សហគមន៍ជនបទ ព្រមទាំងអនុម័តនូវវិធានការទប់ស្កាត់នានា ដើម្បីបញ្ចៀសការទន្ទ្រានយកដី និងការទន្ទ្រានយកទឹក។

ច. កែសម្រួលនិងលុបចោលច្បាប់ដែលមានលក្ខណៈរើសអើង និងការអនុវត្តផ្នែករដ្ឋបាលពាក់ព័ន្ធ ដែលរារាំងដល់ការទទួលស្គាល់ភាពជាម្ចាស់ ឬសិទ្ធិកាន់កាប់ដីធ្លី និងធនធានរបស់ក្រុមមនុស្ស និងបុគ្គលកំពុងរស់ក្នុងភាពក្រីក្រ ជាពិសេស ស្ត្រី។

ឆ. អនុម័តវិធានការលុបបំបាត់រាល់ទម្រង់នៃការអនុវត្តដែលមានការរើសអើង ទាក់ទងនឹងការបែកចែកស្បៀងអាហារនៅក្នុងគ្រួសារ ឬសហគមន៍ ជាពិសេស ទាក់ទងនឹងយេនឌ័រ ឧទាហរណ៍ ដោយការផ្តល់ការគាំទ្រ ផលិតកម្មស្បៀង តាមរយៈស្ត្រី។

ជ. ការពារអ្នកដែលមិនអាចមានលទ្ធភាពក្នុងការចិញ្ចឹមខ្លួនបាន ដោយគួរពិចារណាបង្កើត និងរក្សាបណ្តាញសុវត្ថិភាពស្បៀង ដែលតភ្ជាប់ទៅនឹងអន្តរាគមន៍ដែលអាចបំពេញបន្ថែមគ្នាផ្សេងទៀត ដើម្បីលើកកម្ពស់សន្តិសុខស្បៀងក្នុងរយៈពេលមធ្យមនិងរយៈពេលវែង។ តម្រូវការក្នុងការធានាថា គោលនយោបាយនិងកម្មវិធីជំនួយសង្គម គិតគូពិចារណាទៅលើតម្លៃពិតប្រាកដនៃអាហារូបត្ថម្ភ និងអាហារដែលសមស្របតាមវប្បធម៌។

ឈ. ដោយទទួលស្គាល់បញ្ហាផ្គត់ផ្គង់មិនគ្រប់គ្រាន់ពីទីផ្សារ ធានាឱ្យមានយន្តការបែងចែកប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កលក្ខណៈងាយស្រួលផ្នែករូបវន្តនិងផ្នែកសេដ្ឋកិច្ចដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រទទួលបានស្បៀងអាហារគ្រប់គ្រាន់ តាមវិធីដែលអាចទទួលយកបានតាមវប្បធម៌ និងដោយគ្មានផលប៉ះពាល់អវិជ្ជមានទៅលើកសិករខ្នាតតូច ជនជាតិដើមភាគតិច អ្នកអាស្រ័យផលព្រៃឈើ អ្នកចិញ្ចឹមសត្វ ឬសហគមន៍នេសាទចិញ្ចឹមជីវិតនៅតាមមូលដ្ឋាន ព្រមទាំងស្ត្រី។ ចំណុចនេះ គួររួមបញ្ចូលការត្រួតពិនិត្យឡើងវិញទៅលើប្រព័ន្ធទាំងមូលនៃការកំណត់តម្លៃស្បៀងអាហារ។

៣. ខិតខំព្យាយាមធានាថារាល់គោលនយោបាយពាណិជ្ជកម្ម និងវិនិយោគទាំងអស់ ដោយរួមទាំងគោលនយោបាយដាក់លាក់ចំពោះស្បៀងអាហារ និងកសិកម្ម ត្រូវតែមានភាពអំណោយផលក្នុងការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់ទាំងអស់គ្នា ព្រមទាំងធ្វើសកម្មភាពរួមគ្នាជាលក្ខណៈអន្តរជាតិ ដើម្បី

ដោះស្រាយអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការកើនឡើងនៃតម្លៃស្បៀងអាហារ។ យុទ្ធសាស្ត្រដែលគាំទ្រការអភិវឌ្ឍជនបទផ្អែកលើសិទ្ធិមនុស្ស លើកកម្ពស់ផលិតកម្មស្បៀងប្រកបដោយនិរន្តរភាព និងការបែងចែកស្បៀងដោយសមធម៌ និងការកាត់បន្ថយអស្ថេរភាពទីផ្សារទំនិញដែលប៉ះពាល់ដល់តម្លៃស្បៀងអាហារ ត្រូវតែជាអាទិភាពសម្រាប់រដ្ឋនៅកម្រិតជាតិនិងកម្រិតអន្តរជាតិ។

## ជ. សិទ្ធិទទួលបានទឹកនិងអនាម័យ

77. មនុស្សកំពុងរស់ក្នុងភាពក្រីក្រទទួលរងផលប៉ះពាល់ដោយអសមាមាត្រពីការទទួលបានជាកំហិតនូវទឹក និងអនាម័យសមស្រប។ ទឹកគ្មានសុវត្ថិភាព និងកង្វះការទទួលបានអនាម័យសមស្រប គឺជាបុព្វហេតុចម្បងមួយនៃជំងឺរាគរូស ដែលផ្សាភ្ជាប់ទៅនឹងមរណភាពកុមារនិងទារកក្នុងកម្រិតខ្ពស់នៅក្នុងចំណោមគ្រួសារកំពុងរស់ក្នុងភាពក្រីក្រ ព្រមទាំងរឹតត្បិតការទទួលបានសិទ្ធិដទៃទៀត ដែលរួមបញ្ចូលទាំងសិទ្ធិសុខភាព សិទ្ធិអប់រំ សិទ្ធិការងារ និងឯកជនភាព ហើយដែលវាជាហេតុបណ្តាលឱ្យចុះខ្សោយយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពនៃការគេចចេញពីភាពក្រីក្រ។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ តាំងទីលំនៅក្នុងតំបន់ដែលការទទួលបានទឹកនិង/ឬអនាម័យ មានភាពរឹតត្បិតដោយសារតែតម្លៃចំណាយ កង្វះហេដ្ឋារចនាសម្ព័ន្ធ ការបដិសេធសេវានានាចំពោះអ្នកដែលគ្មានសុវត្ថិភាពខាងការកាន់កាប់ដីធ្លីឬផ្ទះសម្បែង ការគ្រប់គ្រងធនធានមិនបានល្អ ការបំពុលឬការប្រែប្រួលអាកាសធាតុ។ កង្វះការទទួលបានទឹកនិងអនាម័យ មានការប៉ះពាល់ជាពិសេសទៅលើស្ត្រីនិងក្មេងស្រីកំពុងរស់ក្នុងភាពក្រីក្រ។

78. រដ្ឋគួរ៖

ក. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ អាចទទួលបានយ៉ាងហោចណាស់នូវ បរិមាណទឹកចាំបាច់ក្នុងកម្រិតអប្បបរមា ដែលមានភាពគ្រប់គ្រាន់និងមានសុវត្ថិភាព សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននិងការប្រើប្រាស់ក្នុងគ្រួសារ (ដែលរួមបញ្ចូលទាំង សម្រាប់ផឹក អនាម័យផ្ទាល់ខ្លួន ការបោកគក់សម្លៀកបំពាក់ ការរៀបចំម្ហូបអាហារ អនាម័យផ្ទាល់ខ្លួននិងអនាម័យផ្ទះសម្បែង) ព្រមទាំងអនាម័យដែលមានលក្ខណៈគិតគូដល់យេនឌ័រ មានសុវត្ថិភាព បង្កលក្ខណៈងាយស្រួលផ្នែករូបវ័ន្ត និងមានតម្លៃអាចលៃលកបាន។

ខ. គួរដកចេញនូវឧបសគ្គផ្លូវច្បាប់ដែលទាក់ទងនឹងការកាន់កាប់ដីធ្លី នៅក្នុងបរិបទនៃការតាំងទីលំនៅមិនរៀបរយដើម្បីអនុញ្ញាតឱ្យអ្នកតាំងទីលំនៅទទួលបាននូវការតភ្ជាប់បណ្តាញសេវាទឹកនិងសេវាអនាម័យជាផ្លូវការ។ ពុំគួរមានគ្រួសារណាមួយ ត្រូវបានគេបដិសេធសិទ្ធិក្នុងការទទួលបានទឹកនិងអនាម័យ ដោយសារតែមូលហេតុនៃឋានៈខាងលំនៅឋាន ឬដីធ្លីនោះទេ។

គ. ធានាថា មនុស្សគ្មានផ្ទះសម្បែង ទទួលបានទឹកនិងអនាម័យ និងត្រូវជៀសវាងការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ទៅលើសកម្មភាពអនាម័យ រួមមាន ការសម្អាតខ្លួន និងការបន្ទោរបង់នៅតាមទីសាធារណៈ ខណៈដែលសេវាអនាម័យសមស្របមិនមានផ្តល់ឬរកបាននោះ។

ឃ. អនុវត្តវិធានការដើម្បីធានាថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រ មិនត្រូវបានតម្រូវឱ្យបង់ប្រាក់ក្នុងអាត្រាតម្លៃខ្ពស់សម្រាប់សេវាទឹក ដោយសារតែកម្រិតនៃការប្រើប្រាស់នោះទេ។

ង. រៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈទ្រង់ទ្រាយធំអំពីអនាម័យ តាមរយៈ វិធីដែលបង្កលក្ខណៈងាយស្រួលដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## ឈ. សិទ្ធិមានលំនៅឋានសមរម្យ សុវត្ថិភាពនៃការកាន់កាប់ និងការហាមឃាត់ការបណ្តេញចេញដោយបង្ខំ

79. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ រស់នៅក្នុងលក្ខខណ្ឌលំនៅឋានមិនសមរម្យ ដោយរួមមានទាំងសំណង់មិនរៀបរយ និងការតាំងទីលំនៅមិនផ្លូវការ ដោយទទួលបានសេវាចាំបាច់តិចតួចឬគ្មានទាល់តែសោះ។ ភាពចង្អៀតកកកុញ អសន្តិសុខ និងការប្រឈមដោយអសមាមាត្រចំពោះគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះថ្នាក់ពាក់ព័ន្ធនឹងបរិស្ថាន ជាធម្មតា គំរាមកំហែងដល់ជីវិតឬសុខភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ មនុស្សជាច្រើនខ្វះសុវត្ថិភាពនៃការកាន់កាប់ និងរស់នៅក្នុងភាពភ័យខ្លាចជាប្រចាំ ចំពោះមុខនៃការបណ្តេញចេញ និងការដកហូតដីធ្លី ដោយគ្មានមធ្យោបាយសម្រាប់រក្សាការពារសិទ្ធិរបស់ខ្លួនតាមផ្លូវតុលាការឡើយ។ ការរើសអើងក្នុងការទទួលបានលំនៅឋាន កង្វះលំនៅឋានដែលមានតម្លៃអាចលៃលករកទិញបាន និងការប្រមូលទិញផ្ទះនិងដីទុក ជាបន្ថែមលើការរំលោភបំពានបង្កដោយតួអង្គឯកជន ដោយរួមមានទាំង ម្ចាស់ដី ភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនហិរញ្ញវត្ថុ សុទ្ធតែរួមចំណែកឱ្យមានការកើនឡើងនូវភាពងាយរងគ្រោះទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងបានរុញច្រានពួកគេបន្ថែមឱ្យចូលទៅក្នុងភាពទីទ័លក្រ និងភាពគ្មានផ្ទះសម្បែង។ ស្ថិតក្រោមកាលៈទេសៈទាំងនេះ ស្ត្រីទទួលរងបទពិសោធន៍រើសអើងជាច្រើនទម្រង់ ព្រមទាំងប្រឈមនឹងការបំពាននិងអំពើហិង្សា។

80. រដ្ឋគួរ៖

ក. សម្របអាទិភាពទៅលើការកាត់បន្ថយភាពគ្មានផ្ទះសម្បែង តាមរយៈយុទ្ធសាស្ត្រថ្នាក់ជាតិ ខណៈត្រូវបែងចែកធនធានឱ្យបានសមស្រប សម្រាប់ធ្វើការផ្តល់ជម្រកបណ្តោះអាសន្នសមរម្យដល់មនុស្សគ្មានផ្ទះសម្បែងទាំងអស់។

ខ. អនុម័តច្បាប់ការពារដល់បុគ្គល ក្រុមមនុស្ស និងសហគមន៍ទាំងអស់ ដោយរួមទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ប្រឆាំងទៅនឹងការបណ្តេញចេញដោយបង្ខំ ពីសំណាក់តួអង្គរដ្ឋ និងតួអង្គមិនមែនរដ្ឋ។ ចំណុចនេះ គួរបញ្ចូលវិធានការទប់ស្កាត់ដើម្បីជៀសវាងនិង/ឬលុបបំបាត់បុព្វហេតុលាក់កំបាំងស្ថិតនៅពីក្រោយការបណ្តេញចេញដោយបង្ខំ ដូចជា ការចាប់យកដីធ្លីនិងអចលនវត្ថុទុកលក់ចំណេញជាដើម។

គ. សម្របអាទិភាពទៅលើបុគ្គលនិងសហគមន៍កំពុងរស់ក្នុងភាពក្រីក្រ ក្នុងការបែងចែកលំនៅឋាននិងដីធ្លី ជាពិសេស នៅទីកន្លែងដែលអាចរកការងារ និងសេវាផ្សេងៗទៀតបាន។ ការកំណត់បែងចែកបែបនេះ ត្រូវតែធ្វើឡើងតាមវិធីមួយដែលគិតគូដល់យេនឌ័រ ដើម្បីធានាថា បុរសនិងស្ត្រីទទួលបានអត្ថប្រយោជន៍ដោយស្មើភាពគ្នាពីគម្រោងបែបនេះ។

ឃ. ចាត់វិធានការបន្ទាន់ដោយមានគោលបំណងក្នុងការផ្តល់សុវត្ថិភាពផ្លូវច្បាប់ចំពោះការកាន់កាប់ សម្រាប់មនុស្សនិងគ្រួសារកំពុងរស់ក្នុងភាពក្រីក្រដែលខ្វះខាតការគាំពារបែបនេះ ដោយរួមទាំង អ្នកដែលប័ណ្ណកម្មសិទ្ធិលើផ្ទះសម្បែងនិងដីធ្លីរបស់ខ្លួនមិនត្រូវបានទទួលស្គាល់តាមច្បាប់ និងអ្នកដែលកំពុងរស់នៅតាមកន្លែងតាំងទីលំនៅមិនរៀបរយ។

ង. ធានាថា សិទ្ធស្មើភាពគ្នារបស់ស្ត្រីក្នុងការទទួលបានដីធ្លីនិងការកាន់កាប់ ត្រូវបានទទួលស្គាល់និងត្រូវបានអនុវត្ត

ច. ធានាឱ្យមានការចំណាយសាធារណៈគ្រប់គ្រាន់ទៅលើលំនៅឋានដែលមានតម្លៃអាចលៃលកបាន និងលើកកម្ពស់គោលនយោបាយនិងកម្មវិធីដែលជម្រុញដល់ការទទួលបានលំនៅឋានដែលមានតម្លៃអាចលៃលកបានសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ គោលនយោបាយនិងកម្មវិធីបែបនេះ គួរតែស្របទៅនឹងអាទិភាពរបស់ក្រុមដែលរងគុណវិបត្តិបំផុត និងអាចបញ្ចូលកម្មវិធីហិរញ្ញប្បទានលំនៅឋាន ការកែលម្អសំណង់មិនរៀបរយ ការផ្តល់ប័ណ្ណកម្មសិទ្ធិ និងនិយ័តកម្មទៅលើការតាំងទីលំនៅមិនរៀបរយ និង/ឬការឧបត្ថម្ភធនរបស់រដ្ឋ សម្រាប់ការជួលឬឥណទានសម្រាប់ធ្វើជាម្ចាស់លំនៅឋាន។

ឆ. សម្រេបអាទិភាពទៅលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសេវានានានៅក្នុងតំបន់ ដែលតាំងទីលំនៅដោយមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលទាំង ផ្លូវដែលអាចធ្វើដំណើរបានគ្រប់ស្ថានភាពអាកាសធាតុ ទឹកផឹកមានសុវត្ថិភាព សម្ភារៈបរិក្ខារទុកដាក់សំរាម លូបង្ហូរ និងអនាម័យ សម្ភារៈសម្រាប់ការថែទាំសុខភាព និងការអប់រំ ព្រមទាំងភ្លើងអគ្គិសនី។

ជ. រៀបចំបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទាក់ទងទៅនឹងលំនៅឋាន ដោយមានការគិតគូដល់សិទ្ធិរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ កិច្ចប្រឹងប្រែងក្នុងការស្តារនីតិសម្បទា ក្រោយគ្រោះមហន្តរាយ គួរដាក់បញ្ចូលវិធានការដើម្បីពង្រឹងសុវត្ថិភាពនៃការកាន់កាប់សម្រាប់មនុស្សដែលមានស្ថានភាពអសន្តិសុខខាងការកាន់កាប់ដីធ្លីឬលំនៅឋាន និងសម្រេបអាទិភាពទៅលើការកសាងលំនៅឋានឡើងវិញនិងការផ្តល់លំនៅឋានជំនួស ដូចជាលំនៅឋានលក្ខណៈសង្គមកិច្ច ឬលំនៅឋានសាធារណៈសម្រាប់ក្រុមដែលទទួលរងគុណវិបត្តិបំផុត។

## ៣. សិទ្ធិទទួលបានស្តង់ដារសុខភាពផ្លូវកាយនិងផ្លូវចិត្ត ឱ្យបានខ្ពស់តាមអាចសម្រេចបាន

81. នៅក្នុងឧទាហរណ៍ច្បាស់មួយនៃវដ្តដ៏អាក្រក់នៃភាពក្រីក្រនេះ មនុស្សដែលកំពុងជួបបទពិសោធន៍សុខភាពមិនល្អ ទំនងជាក្លាយទៅជាអ្នកក្រីក្រ ខណៈដែលមនុស្សកំពុងរស់ក្នុងភាពក្រីក្រងាយរងគ្រោះជាងអ្នកផ្សេងទៀតចំពោះគ្រោះថ្នាក់ ជំងឺតម្កាត់ និងពិការភាព។ ការទទួលបានដ៏កំហិតនូវការថែទាំសុខភាពរាងកាយនិងផ្លូវចិត្ត ដោយមានទាំង ថ្នាំសង្កូវ អាហារូបត្ថម្ភមិនគ្រប់គ្រាន់ និងបរិយាកាសរស់នៅគ្មានសុវត្ថិភាពផងនោះ វាបានជះឥទ្ធិពលយ៉ាងអាក្រក់ទៅលើសុខភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងធ្វើឱ្យខូចខាតដល់សមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងសកម្មភាពរកប្រាក់ចំណូល ឬការចិញ្ចឹមជីវិតប្រកបដោយផលិតភាព។ ស្ត្រីនិងក្មេងស្រី មានការទទួលខុសត្រូវយ៉ាងអសមាមាត្រលើកាងារថែទាំ ខណៈទីកន្លែងដែលមានសម្ភារៈបរិក្ខារផ្តល់ការថែទាំសុខភាព នៅមានការខ្វះខាត ឬមិនបង្កលក្ខណៈងាយស្រួលដល់ការទៅប្រើប្រាស់ ហេតុដូច្នេះ ជាញឹកញយបំផុត ពួកគេត្រូវបោះបង់ការសិក្សា ឬការងារផ្លូវការដើម្បីទៅផ្តល់ការថែទាំវិញ។

82. រដ្ឋគួរ៖

ក. ចាត់វិធានការដែលវិសាលភាពមានលក្ខណៈពហុភាព ដើម្បីលុបបំបាត់ទំនាក់ទំនងរវាងសុខភាពមិនល្អនិងភាពក្រីក្រ តាមរយៈការទទួលស្គាល់កត្តាកំណត់ផ្សេងៗគ្នាជាច្រើនអំពីសុខភាព និងទីភ្នាក់ងារ ព្រមទាំងស្វ័យភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

ខ. បង្កើនភាពងាយស្រួល និងបង្កើនគុណភាពនៃការថែទាំសុខភាព ដោយផ្តោតទាំងលើការទប់ស្កាត់និងការព្យាបាលជំងឺសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលទាំងការថែទាំសុខភាពផ្លូវភេទនិងបន្តពូជ និងការថែទាំសុខភាពផ្លូវចិត្ត។

គ. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ទទួលបានថ្នាំសង្កូវមានសុវត្ថិភាពនិងមានតម្លៃអាចលៃលកបាន និងធានាថា ការដែលគ្មានលទ្ធភាពបង់ថ្លៃចំណាយ មិនរារាំងដល់ការទទួលបានការថែទាំសុខភាពនិងថ្នាំសង្កូវសំខាន់ចាំបាច់នោះទេ។

ឃ. បង្កើតទីកន្លែងដែលមានសម្ភារៈបរិក្ខារផ្តល់ការថែទាំសុខភាព នៅលើទីតាំងដែលសហគមន៍កំពុងរស់ក្នុងភាពក្រីក្រ អាចទៅប្រើប្រាស់បានដោយសុវត្ថិភាព រួមបញ្ចូលទាំងនៅតាមទីជនបទ និងតំបន់សំណង់មិនរៀបរយ ព្រមទាំងធានាថាទីកន្លែងទាំងអស់នេះ មានធនធានទាំងអស់ដែលចាំបាច់សម្រាប់ដំណើរការបានយ៉ាងសមស្រប។

ង. ចាត់វិធានការពិសេស ដោយផ្តោតទៅលើលក្ខខណ្ឌសុខភាពចម្បងៗដែលប៉ះពាល់ទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ រួមទាំងផ្តោតលើជំងឺមួយចំនួនដែលមិនត្រូវបានយកចិត្តទុកដាក់។ ប្រការនេះ គួរបញ្ចូលកម្មវិធីចាក់ថ្នាំបង្ការដោយមិនគិតកម្រៃ កម្មវិធីអប់រំនិងបណ្តុះបណ្តាលដល់ប្រតិបត្តិករសុខាភិបាល ដើម្បីកំណត់រោគសញ្ញានិងព្យាបាលជំងឺបែបនេះ។

ច. អនុវត្តគោលនយោបាយជាក់លាក់និងមានធនធានគ្រប់គ្រាន់ ដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ ដែលរួមបញ្ចូលទាំង សេវាបង្ការនិងព្យាបាលដែលបង្កលក្ខណៈងាយស្រួលនិងដែលគាំពារដល់សេចក្តីថ្លៃថ្នូរនិងឯកជនភាពរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

ឆ. ផ្តល់សេវាដែលរៀបចំសមស្របសម្រាប់ក្រុមមនុស្សដែលការទទួលសេវាសុខភាពអាចមានបញ្ហាប្រឈមជាក់លាក់ ដូចជា ភាសា ឧបសគ្គទាក់ទងនឹងទីតាំងភូមិសាស្ត្រ ឧបសគ្គផ្អែកវប្បធម៌ អាយុ ការរើសអើង ឬស្ថានភាពសុខភាពបច្ចុប្បន្ន។ ស្ត្រីកំពុងរស់នៅក្នុងភាពក្រីក្រ គួរទទួលបានសេវាសុខភាពនិងព័ត៌មានអំពីសុខភាពផ្លូវភេទនិងបន្តពូជដែលមានគុណភាពខ្ពស់។

### ជ. សិទ្ធិទទួលបានការងារនិងសិទ្ធិនៅកន្លែងការងារ

83. ក្នុងតំបន់ទីក្រុងក៏ដូចជាតំបន់ជនបទដែរ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជួបប្រទះភាពគ្មានការងារធ្វើ មានការងារធ្វើតិចតួច ការងារប្រើកម្លាំងមានភាពមិនជាប់លាប់ដែលមិនអាចទុកចិត្តបាន ប្រាក់ឈ្នួលទាប និងលក្ខខណ្ឌការងារគ្មានសុវត្ថិភាពនិងបែបបន្ទាបបន្ថោក។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ច្រើនតែធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងមិនមានអត្ថប្រយោជន៍របបសន្តិសុខសង្គម ដូចជា ការឈប់សម្រាកលំហែមាតុភាព ការឈប់សម្រាកពេលឈឺ ប្រាក់សោធននិវត្តន៍ និងពិការភាពឡើយ។ ពួកគេអាចនឹងចំណាយពេលវេលាក្នុងម៉ោងធ្វើការភាគច្រើននៅកន្លែងការងារ ហើយសឹងតែមិនអាចរកចំណូលគ្រប់គ្រាន់មកចិញ្ចឹមជីវិតបាន ព្រមទាំងប្រឈមនឹងការកេងប្រវ័ញ្ច ដោយរួមទាំង ការងារដើម្បីដោះបំណុល ឬការងារដោយបង្ខំ ការបណ្តេញចេញតាមទំនើងចិត្ត និងការរំលោភបំពាន។ ស្ត្រីមានហានិភ័យជាពិសេសចំពោះការរំលោភបំពាន ដែលដូចគ្នានឹងក្រុមទទួលរងផលប៉ះពាល់ពីការរើសអើង មានដូចជា ជនមានពិការភាព និងជនចំណាកស្រុកគ្មានឯកសារគ្រប់គ្រាន់។ ជាធម្មតា ស្ត្រីទទួល

បន្ទុកការងារគ្មានប្រាក់កម្រៃទាំងស្រុងនៅក្នុងផ្ទះសម្បែង ដែលធ្វើឱ្យពួកគេទំនងជានឹងបានចូលរួមតែនៅក្នុងការងារដែលមានប្រាក់ឈ្នួលទាប និងការងារដែលអសន្តិសុខ ឬរាំងពួកគេពីការចូលទៅក្នុងទីផ្សារការងារទាំងស្រុង។

84. រដ្ឋគួរ៖

ក. អនុម័តបទប្បញ្ញត្តិការងាររឹងមាំ និងធានាថាមានការអនុវត្តដោយផ្នែកអធិការកិច្ចការងារដែលមានសមត្ថភាពនិងធនធានគ្រប់គ្រាន់ ដើម្បីធានាដល់ការទទួលបានសិទ្ធិមានលក្ខខណ្ឌការងារសមរម្យ។

ខ. ធានាថា រាល់កម្មករទាំងអស់ទទួលបានប្រាក់ឈ្នួលសមរម្យ ដើម្បីឱ្យពួកគេនិងគ្រួសារទទួលបាននូវស្តង់ដាររស់នៅសមរម្យ។

គ. ធានាថាស្តង់ដារផ្លូវច្បាប់ទាក់ទងនឹងលក្ខខណ្ឌការងារដែលមានភាពយុត្តិធម៌ និងមានការគាំទ្រដល់កម្មករ ត្រូវបានគោរព និងពង្រីកវិសាលភាពទៅដល់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងប្រមូលទិន្នន័យបែងចែកតាមប្រភេទដើម្បីធ្វើការប៉ាន់ប្រមាណអំពីទំហំវិសាលភាពនៃការងារក្រៅប្រព័ន្ធ។

ឃ. ចាត់វិធានការវិជ្ជមានដើម្បីធានាឱ្យមានការលុបបំបាត់រាល់ទម្រង់នៃការងារដោយបង្ខំ និងការងារដោះបំណុល ព្រមទាំងទម្រង់នៃពលកម្មកុមារដែលបង្កការអន្តរាយនិងមានគ្រោះថ្នាក់ បន្ថែមទៅលើវិធានការដែលធានាឱ្យមានការធ្វើសមាហរណកម្មសង្គមនិងសេដ្ឋកិច្ចសម្រាប់មនុស្សដែលទទួលរងផលប៉ះពាល់ និងត្រូវជៀសវាងពីការកើតឡើងវិញម្តងទៀត។

ង. ធានាថា អ្នកផ្តល់ការថែទាំទទួលបានការគាំពារនិងគាំទ្រគ្រប់គ្រាន់ ដោយកម្មវិធីនិងសេវាកម្មសង្គម ដែលរួមមានទាំងការទទួលបានការថែទាំកុមារដែលមានតម្លៃអាចលៃលកបាន។

ច. ដាក់ឱ្យអនុវត្តវិធានការជាក់លាក់ដើម្បីពង្រីកឱកាសសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ក្នុងការស្វែងរកការងារសមរម្យនៅក្នុងទីផ្សារការងារផ្លូវការ ដោយរួមបញ្ចូលទាំងតាមរយៈការណែនាំនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងឱកាសអភិវឌ្ឍជំនាញផ្សេងៗ។

ឆ. លុបបំបាត់ការរើសអើងក្នុងការទទួលបានការងារនិងការបណ្តុះបណ្តាល ព្រមទាំងធានាថា កម្មវិធីបណ្តុះបណ្តាលបង្កលក្ខណៈងាយស្រួលដល់អ្នកដែលងាយរងគ្រោះបំផុតទៅនឹងភាពក្រីក្រ និងភាពគ្មានការងារធ្វើ មានរួមទាំង ស្ត្រី ជនចំណាកស្រុក និងជនមានពិការភាព ព្រមទាំងរៀបចំសម្របឱ្យត្រូវនឹងតម្រូវការរបស់ពួកគេ។

ជ. គោរព លើកកម្ពស់ និងសម្រេចឱ្យបាននូវសេរីភាពខាងសមាគម ដើម្បីឱ្យអត្តសញ្ញាណ សម្លេង និងភាពជាតំណាងរបស់កម្មករកំពុងរស់ក្នុងភាពក្រីក្រ អាចត្រូវបានពង្រឹងនៅក្នុងកិច្ចសន្ទនាលក្ខណៈសង្គម និងនយោបាយលើបញ្ហាកំណែទម្រង់វិស័យការងារ។

## ឋ. សិទ្ធិទទួលបានរបបសន្តិសុខសង្គម

85. មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ មិនអាចទទួលបានសិទ្ធិរបបសន្តិសុខសង្គមទេ។ ខណៈដែលសិទ្ធិនេះរួមបញ្ចូលការធានារ៉ាប់រងសង្គម (ជាគម្រោងភាគទាន) និងជំនួយគាំទ្រសង្គមកិច្ច (គម្រោងគ្មានភាគទាន) រដ្ឋភាគច្រើនពឹងផ្អែកតែទៅលើប្រព័ន្ធភាគទាន ជាប្រភពសំខាន់នៃការផ្តល់អត្ថប្រយោជន៍សន្តិសុខសង្គម ដោយ

ក្នុងនោះ កម្មវិធីជំនួយគាំទ្រសង្គមកិច្ច ជារឿយៗ ពុំមានភាពគ្រប់គ្រាន់ និងពុំសូវមានប្រសិទ្ធភាពទេ។ ដោយសារតែមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ច្រើនតែធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ធ្វើការងារដែលគ្មានសុវត្ថិភាព និងមានប្រាក់ឈ្នួលទាប គ្មានការងារធ្វើរយៈពេលវែង ឬមិនអាចធ្វើការងារបាននោះ ពួកគេច្រើនតែមិនអាចរួមចំណែកបង់ភាគទានបានទេ ហេតុដូច្នេះហើយ ពួកគេមិនទទួលបានអត្ថប្រយោជន៍ខាងធានារ៉ាប់រងសង្គមទេ មានដូចជាអត្ថប្រយោជន៍ពីប្រាក់សោធននិវត្តន៍ និកម្មភាព និងពេលមានជំងឺ។ បញ្ហាទាំងអស់នេះមានភាពធ្ងន់ធ្ងរ ដោយឡែកសម្រាប់ស្ត្រី ដោយសារការរើសអើងនិងទំនួលខុសត្រូវក្នុងការងារថែទាំ ដែលធ្វើឱ្យពួកគេទទួលបានប្រាក់ឈ្នួលទាប និងមានប្រវត្តិការងារមិនជាប់លាប់ ដែលជាការកាត់បន្ថយសមត្ថភាព ក្នុងការរួមចំណែកនិងទទួលអត្ថប្រយោជន៍ពីគម្រោងធានារ៉ាប់រងសង្គម។

86. រដ្ឋគួរ៖

ក. រៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមគ្រប់ជ្រុងជ្រោយមួយ និងបែងចែកផ្តល់ធនធានចាំបាច់ដើម្បីធានា តាមភាពរីកចម្រើនរបស់ខ្លួន ក្នុងការទទួលបានជាសាកលនូវសន្តិសុខសង្គមសម្រាប់មនុស្សទាំងអស់គ្នា និងការទទួលបានយ៉ាងហោចណាស់ក្នុងកម្រិតចាំបាច់អប្បបរមានៃសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌។ ទោះបីជាមនុស្សទាំងអស់គួរតែទទួលបានប្រព័ន្ធសន្តិសុខសង្គមតាមភាពរីកចម្រើនក៏ដោយ ក៏អាទិភាពគួរតែសម្របទៅលើក្រុមមនុស្សដែលរងគុណវិបត្តិបំផុតនិងក្រុមដែលត្រូវបានផាត់ចេញពីសង្គម។

ខ. ដាក់ឱ្យអនុវត្តនិងពង្រីកប្រព័ន្ធសន្តិសុខសង្គមគ្រប់ជ្រុងជ្រោយដែលផ្តល់មូលនិធិពីថ្នាក់ជាតិ ដែលគ្របដណ្តប់លើការធានារ៉ាប់រងសង្គមនិងជំនួយសង្គម ស្របតាមអនុសាសន៍របស់អង្គការអន្តរជាតិខាងការងារ ស្តីពីកិច្ចគាំពារសង្គមអប្បបរមា។

គ. ចាត់វិធានការជាក់លាក់ដើម្បីធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយលែកស្ត្រី និងអ្នកដែលកំពុងធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទទួលបានអត្ថប្រយោជន៍ខាងរបបសន្តិសុខសង្គម ដែលរួមបញ្ចូលទាំងប្រាក់សោធនិវត្តន៍ ដែលគ្រប់គ្រាន់នៅក្នុងការធានាបាននូវស្តង់ដាររស់នៅសមរម្យ និងការទទួលបានការថែទាំសុខភាពសម្រាប់ពួកគេនិងក្រុមគ្រួសាររបស់ពួកគេ។

ឃ. ធានាថា ប្រព័ន្ធរបបសន្តិសុខសង្គម ត្រូវបានបង្កើតឡើងដោយច្បាប់ តាមវិធីដែលមានតម្លាភាព មាននិរន្តរភាព និងបរិយាប័ន្ន និងជាផ្នែកដាច់ដោយលែកមួយនៃផែនការជាតិដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានភាពស៊ីសង្វាក់គ្នា សម្រាប់លុបបំបាត់ភាពក្រីក្រ។

ង. ធានាថាប្រព័ន្ធរបបសន្តិសុខសង្គម ត្រូវបានរៀបចំបង្កើតឡើង អនុវត្ត និងវាយតម្លៃ ដោយពិចារណាទៅលើតម្រូវការជាក់លាក់របស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជាពិសេសស្ត្រី។

## ឌ. សិទ្ធិទទួលបានការអប់រំ

87. កុមារកំពុងរស់ក្នុងភាពក្រីក្រ ច្រើនតែបោះបង់ការសិក្សាឬមិនដែលបានចូលរៀនទាល់តែសោះ ដើម្បីបានទៅចូលរួមនៅក្នុងសកម្មភាពរកប្រាក់ចំណូលឬដើម្បីជួយការងារផ្ទះ។ ការអប់រំគឺជាមធ្យោបាយដ៏សំខាន់បំផុតមួយដែលមនុស្សអាចអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងសមត្ថភាព ដើម្បីសម្រេចសក្តានុពលពេញលេញ

បង្កើនឱកាសក្នុងការស្វែងរកការងារ ចូលរួមកាន់តែមានប្រសិទ្ធភាពនៅក្នុងសង្គម ព្រមទាំងក្នុងការគេចចេញពីភាពក្រីក្រ។ ដូច្នេះ ផលវិបាកផ្នែកសេដ្ឋកិច្ចដោយសារតែមិនបានបញ្ចប់បឋមសិក្សាឬមធ្យមសិក្សា ជាការបង្កក្តីអន្តរាយ និងធ្វើឱ្យវដ្តនៃភាពក្រីក្របន្តកើតមានឡើងមិនដាច់។ ជាធម្មតា ក្មេងស្រីត្រូវបានបដិសេធសិទ្ធិទទួលបានការអប់រំ ជាងក្មេងប្រុស ហើយជាលទ្ធផល ធ្វើឱ្យរឹតត្បិតជម្រើសរបស់ពួកគេនិងបង្កើនភាពក្រីក្រសម្រាប់ស្ត្រី ។

៤៨. វដ្តគួរៈ

ក. ធានាថាកុមារទាំងអស់ រួមទាំងកុមារកំពុងរស់ក្នុងភាពក្រីក្រ មានលទ្ធភាពទទួលបានសិទ្ធិអប់រំកម្រិតបឋមសិក្សាជាកាតព្វកិច្ចនិងមិនបង់ប្រាក់កម្រៃ តាមរយៈការផ្តល់ការអប់រំដែលមានគុណភាពខ្ពស់នៅសាលារៀន ដែលពួកគេអាចធ្វើដំណើរទៅដល់បានដោយសុវត្ថិភាព និងដោយមិនមានការបង់ប្រាក់កម្រៃជាប្រយោលផ្សេងៗឡើយ។

ខ. ផ្តល់សាលារៀននៅក្នុងតំបន់ដែលរងនូវគុណវិបត្តិ ដោយមាននូវគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាល និងមានគុណភាពខ្ពស់ ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដោយរួមមានទាំង សម្ភារៈបរិក្ខារអនាម័យដែលគិតគូដល់យេនឌ័រ ទឹក និងភ្លើងអគ្គិសនី។

គ. តាមភាពរីកចម្រើន ចាត់វិធានការដើម្បីធានាឱ្យមាននូវការអប់រំគ្រប់ទម្រង់ និងនៅគ្រប់កម្រិត ដែលបង្កលក្ខណៈងាយស្រួល អាចរកបាន ទទួលយកបាន សម្របបាន និងប្រកបដោយគុណភាព ។ ចំណុចនេះរួមបញ្ចូលទាំងការកំណត់ជាអាទិភាព ការបែងចែកធនធានឱ្យដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដើម្បីសងទូទាត់ទៅដល់គុណវិបត្តិផ្នែកសេដ្ឋកិច្ចសង្គមរបស់ពួកគេ (ឧទាហរណ៍ វិធានការបុរេសកម្ម ដើម្បីបំបាត់អត្រានៃការបោះបង់ការសិក្សា ការផ្តល់ជំនួយឥតសំណង និងការផ្តល់អាហារនៅសាលារៀន។

ឃ. ចាត់វិធានការ តាមភាពរីកចម្រើនរបស់ខ្លួន ដើម្បីណែនាំឱ្យមានការអប់រំដោយមិនបង់ប្រាក់ សម្រាប់កម្រិតមធ្យមសិក្សានិងកម្រិតខ្ពស់ ដោយលែក សម្រាប់ក្មេងស្រី និងក្រុមមនុស្សដែលងាយរងគ្រោះចំពោះភាពក្រីក្រ និងការផាត់ចេញពីសង្គម ដូចជាកុមារមានពិការភាព ក្រុមនិគមជនភាគតិច ជនភៀសខ្លួន កូនរបស់ជនចំណាកស្រុកដែលគ្មានឯកសារគ្រប់គ្រាន់ ជនគ្មានសញ្ជាតិ (គ្មានរដ្ឋ) កុមារកំពុងរស់នៅតាមមជ្ឈមណ្ឌលនានា និងមនុស្សកំពុងរស់នៅតាមតំបន់ដាច់ស្រយាល និងសំណង់មិនរៀបរយ។

ង. ត្រួតពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មច្បាប់ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នារវាងអាយុអប្បបរមាដែលត្រូវចាកចោលសាលារៀន និងអាយុអប្បបរមាក្នុងការរៀបអាពាហ៍ពិពាហ៍ និងក្នុងការទទួលបានការងារធ្វើ។

ច. ផ្តល់មជ្ឈមណ្ឌលអប់រំកម្រិតមត្តេយ្យសិក្សាដែលមានគុណភាពខ្ពស់ ដើម្បីកែលម្អការអប់រំនិងសុខភាពរបស់កុមារកំពុងរស់ក្នុងភាពក្រីក្រ។

ជ. ចាត់វិធានការដើម្បីលុបបំបាត់អនក្ខរភាព ដោយរួមបញ្ចូលទាំង សម្រាប់មនុស្សពេញវ័យផងដែរ។

ឈ. ធានាថាមនុស្សកំពុងរស់ក្នុងភាពក្រីក្រ មានលទ្ធភាពយល់ដឹង ស្វែងរក និងទទួលព័ត៌មានអំពីសិទ្ធិមនុស្សនិងសេរីភាពជាសារវន្តទាំងអស់ ព្រមទាំងទទួលបានការអប់រំនិងការបណ្តុះបណ្តាលសិទ្ធិមនុស្ស។

## ឈ. សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ និងទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកវិទ្យាសាស្ត្រនិងការអនុវត្តបែបវិទ្យាសាស្ត្រ

៨៩. ភាពក្រីក្របានរឹតត្បិតយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថភាពរបស់បុគ្គលឬក្រុមមនុស្សនានា ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដើម្បីចូលរួម ទទួលបាន និង រួមចំណែក ទៅលើគ្រប់វិស័យទាំងអស់នៃជីវភាពវប្បធម៌ ក៏ដូចជាសមត្ថភាពក្នុងការរីករាយនឹងវប្បធម៌ផ្ទាល់របស់ខ្លួន និងវប្បធម៌របស់អ្នកដទៃប្រកបដោយប្រសិទ្ធភាព ដែលនេះគឺជាការធ្វើឱ្យកាន់តែមានភាពធ្ងន់ធ្ងរឡើងទៅដល់ការដកហូតភាពអង់អាច និងការផាត់ចេញពីសង្គម។ ការសម្តែងទស្សនៈផ្នែកវប្បធម៌ដោយសេរី តាមរយៈគុណតម្លៃ ជំនឿ មតិយោបល់ ភាសា ចំណេះដឹង និងសិល្បៈ ស្ថាប័ននិងរបៀបរបបរស់នៅ បង្កលក្ខណៈឱ្យមនុស្សរស់នៅក្នុងភាពក្រីក្រ អាចបង្ហាញពីភាពជាមនុស្សរបស់ពួកគេ ទស្សនៈអំពីពិភពលោករបស់ពួកគេ បេតិកភណ្ឌវប្បធម៌ និងអត្ថន័យ ដែលពួកគេបានផ្តល់សម្រាប់អត្ថិភាព និងការអភិវឌ្ឍរបស់ខ្លួន។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ជារឿយៗ ពុំអាចទទួលអត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងការអនុវត្តផ្នែកវិទ្យាសាស្ត្រដោយស្មើភាពគ្នានោះទេ។

៩០. រដ្ឋគួរ

ក. ទទួលស្គាល់និងផ្តល់តម្លៃទៅលើភាពចម្រុះនៃបេតិកភណ្ឌវប្បធម៌ ដែលមានវត្តមាននៅលើដែនដីរបស់ពួកគេនិងក្រោមសមត្ថកិច្ចរបស់ពួកគេ ដែលរួមបញ្ចូលទាំងបេតិកភណ្ឌវប្បធម៌របស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រដែរ។

ខ. គោរពនិងគាំពារបេតិកភណ្ឌវប្បធម៌របស់ក្រុមនានាកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលតាមតាមរយៈការការពារឱ្យរួចផុតពីការកេងប្រវ័ញ្ចខុសច្បាប់ និងដោយអយុត្តិធម៌ទៅលើដីធ្លី ដែនដី និងធនធានរបស់ជនជាតិដើមភាគតិច ដោយភ្នាក់ងាររដ្ឋ ឬតួអង្គមិនមែនរដ្ឋ ដែលរួមបញ្ចូលទាំងសាជីវកម្មឆ្លងដែន និងសហគ្រាសធុរកិច្ចដទៃទៀតដែរ។

គ. ធានាថា គោលនយោបាយ និងកម្មវិធីបេតិកភណ្ឌវប្បធម៌ មានរួមទាំងកម្មវិធីនិងគោលនយោបាយដែលរៀបចំឡើងដើម្បីលើកកម្ពស់វិស័យទេសចរណ៍ ព្រមទាំងតាមរយៈការចូលរួមដោយសកម្មរបស់សហគមន៍និងបុគ្គលដែលពាក់ព័ន្ធផង មិនត្រូវអនុវត្តធ្វើឱ្យប៉ះពាល់ឬខូចប្រយោជន៍សហគមន៍កំពុងរស់ក្នុងភាពក្រីក្រឡើយ។

ឃ. បង្កើតឱកាសសម្រាប់មនុស្សកំពុងរស់ក្នុងភាពក្រីក្រឱ្យបានចូលរួម ឱ្យទទួលបាន និងឱ្យរួមចំណែកដល់ជីវភាពវប្បធម៌ ដោយរួមទាំងការសម្រួលដល់ការទទួលបានលំហសាធារណៈដែលបុគ្គលនិងក្រុមនានាពីសហគមន៍ទាំងអស់ អាចរៀបចំសកម្មភាពច្នៃប្រឌិតនិងសកម្មភាពកម្សាន្ត ប្រមូលផ្តុំដើម្បីអនុវត្តពិធីនានា ព្រមទាំងចូលរួមជាមួយគ្នាទៅវិញទៅមក។ រដ្ឋក៏គួរជួយសម្រួលដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ឱ្យទទួលបានទំនិញវប្បធម៌ សេវាកម្មវប្បធម៌ និងស្ថាប័នវប្បធម៌ផងដែរ។

ង. ចាត់វិធានការវិជ្ជមានដើម្បីធានាថា អត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ បានទៅដល់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ហើយធានាឱ្យមានការទទួលបានព័ត៌មាន ដំណើរការ និងផលិតផលដែលមានលក្ខណៈវិទ្យាសាស្ត្រទាំងអស់នេះ។

ច. ធានាថា នវានុវត្តន៍សំខាន់ចាំបាច់ដែលជួយឱ្យជីវិតរស់ក្នុងសេចក្តីថ្លៃថ្នូរ មានការបង្កលក្ខណៈងាយស្រួលផ្នែករូបវន្ត និងមានតម្លៃអាចលៃលកបាន ដោយឈរលើមូលដ្ឋាននៃការមិនរើសអើងចំពោះមនុស្សគ្រប់រូប រួមទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

## VI. កាតព្វកិច្ចនៃជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ

91. រដ្ឋមានកាតព្វកិច្ចផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របតាមសមត្ថភាពធនធាន ឥទ្ធិពលរបស់ខ្លួន ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ (មាត្រា 55 និង 56) និងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនទៀត

92. ជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ រដ្ឋមានកាតព្វកិច្ចនៅក្នុងការគោរព និងការពារចំពោះការទទួលបានសិទ្ធិមនុស្ស ដែលក្នុងនោះត្រូវជៀសវាងទង្វើដែលអាចប្រមើលដឹងបានថានឹងបង្កើតហានិភ័យនៃការធ្វើឱ្យខូចខាតដល់ការទទួលបានសិទ្ធិមនុស្សរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដែលស្ថិតនៅក្រៅព្រំដែនរបស់ខ្លួន ព្រមទាំងធ្វើការប៉ាន់ប្រមាណអំពីផលប៉ះពាល់ផ្នែកច្បាប់ គោលនយោបាយ និងការអនុវត្ត នៅក្រៅដែនដី។

93. រដ្ឋដែលស្ថិតក្នុងតួនាទីត្រូវធ្វើកិច្ចការនេះ គួរផ្តល់ជំនួយអន្តរជាតិ ដើម្បីរួមចំណែកដល់ការបំពេញសិទ្ធិមនុស្ស និងកាត់បន្ថយភាពក្រីក្រ ដែលជាចំណែកភារកិច្ចមួយនៃជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ជំនួយអន្តរជាតិគួរគោរពភាពជាម្ចាស់របស់ប្រទេសដៃគូ អំពីយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្ររបស់ពួកគេ ព្រមទាំងគួរតម្រឹមតាមយុទ្ធសាស្ត្រ ស្ថាប័ន និងនីតិវិធីអភិវឌ្ឍន៍ជាតិ។ សកម្មភាពរបស់ម្ចាស់ជំនួយនានាគួរមានភាពសុខដុមរមនា មានតម្លាភាព និងមានការសម្របសម្រួល ហើយទាំងម្ចាស់ជំនួយនិងទាំងដៃគូ គួរមានគណនេយ្យភាពចំពោះសកម្មភាពនិងលទ្ធផលនៃកិច្ចអន្តរាគមន៍របស់ខ្លួន។

94. រដ្ឋមានកាតព្វកិច្ចនៅក្នុងការស្វែងរកជំនួយអន្តរជាតិ តាមលក្ខខណ្ឌយល់ព្រមជាមួយគ្នាទៅវិញទៅមក នៅពេលដែលពួកគេមិនអាចធានាបានថា មនុស្សកំពុងរស់ក្នុងភាពក្រីក្រនៅក្នុងដែនដីខ្លួនទទួលបានសិទ្ធិមនុស្ស ទោះបីជាបានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពហើយក្តី។ រដ្ឋត្រូវតែធានាថា ជំនួយដែលផ្តល់ឱ្យនោះត្រូវបានប្រើប្រាស់និងគ្រប់គ្រងស្របទៅតាមគោលការណ៍សិទ្ធិមនុស្ស។

95. នៅក្នុងការផ្តល់និងការទទួលជំនួយអន្តរជាតិ រដ្ឋគួរធានាឱ្យមានការចូលរួមដោយប្រសិទ្ធភាពពីរដ្ឋទទួលជំនួយ ព្រមទាំងភាគីទទួលរងផលប៉ះពាល់ទាំងអស់ ដោយរាប់បញ្ចូលទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ព្រមទាំងពង្រឹងសមត្ថភាពនិងភាពជាម្ចាស់របស់ពួកគេ នៅក្នុងបរិបទជំនួយអន្តរជាតិ។

96. រដ្ឋត្រូវចាត់វិធានការដោយមានចេតនាជាក់លាក់និងមានគោលដៅច្បាស់លាស់ ទោះតែឯងក្តី ឬដោយរួមគ្នាក្តី ក្នុងការបង្កើតនូវបរិយាកាសអំណោយផលជាលក្ខណៈអន្តរជាតិ ចំពោះការកាត់បន្ថយភាពក្រីក្រ ដោយរួមបញ្ចូលទាំងបញ្ហានានាទាក់ទងនឹងពាណិជ្ជកម្មទ្វេភាគីនិងពហុភាគី ការវិនិយោគ ពន្ធគយ ហិរញ្ញវត្ថុ ការគាំពារបរិស្ថាននិងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ កិច្ចការនេះរួមមានទាំងការសហការក្នុងការកៀងគរធនធានដែលអាចរកបានឱ្យដល់កម្រិតអតិបរមា សម្រាប់ការបំពេញសិទ្ធិមនុស្សជាលក្ខណៈសាកល។

97. សូម្បីតែនៅក្នុងឋានៈជាសមាជិករបស់អង្គការអន្តរជាតិណាមួយក៏ដោយ ក៏រដ្ឋនៅតែជាអ្នកទទួលខុសត្រូវសម្រាប់ការអនុវត្តរបស់ខ្លួន ទាក់ទងនឹងកាតព្វកិច្ចសិទ្ធិមនុស្សនៅក្នុងនិងនៅក្រៅដែនដីរបស់ខ្លួនដែរ។ ការទទួលខុសត្រូវនេះ រួមបញ្ចូលទាំងការកំណត់រកឱ្យឃើញនូវផលប៉ះពាល់ផ្នែកសិទ្ធិមនុស្សដែលអាចកើតឡើងពីវិធានការដែលបានយល់ស្របគ្នានៅកម្រិតអន្តរជាតិ ដូចជាទៅលើមនុស្សកំពុងរស់ក្នុងភាពក្រីក្រ។

98. រដ្ឋដែលអាចផ្ទេរសមត្ថភាពឬចូលរួមនៅក្នុងអង្គការអន្តរជាតិណាមួយ ត្រូវតែចាត់រាល់វិធានការទាំងអស់ប្រកបដោយហេតុផលសមស្រប ដើម្បីធានាថា អង្គការពាក់ព័ន្ធអនុវត្តស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋនោះ និងតាមវិធីមួយដែលអំណោយផលដល់ការកាត់បន្ថយភាពក្រីក្រ។

## VII. តួនាទីរបស់តួអង្គមិនមែនរដ្ឋ រួមទាំងសហគ្រាសធុរកិច្ច

99. រដ្ឋមានភារកិច្ចស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន នៅក្នុងការទប់ស្កាត់និងការពារប្រឆាំងនឹងការបំពានសិទ្ធិមនុស្សដែលប្រព្រឹត្តដោយតួអង្គមិនមែនរដ្ឋ រួមបញ្ចូលទាំងសហគ្រាសធុរកិច្ច ដែលពួកគេមានតួនាទីធ្វើនិយ័តកម្ម។ នៅទីណាដែលមានការចូលពាក់ព័ន្ធពីសាជីវកម្មឆ្លងដែន រដ្ឋជាប់ពាក់ព័ន្ធទាំងអស់ គួរសហការគ្នាដើម្បីធានាថា ធុរកិច្ចទាំងនោះគោរពសិទ្ធិមនុស្សនៅបរទេស ដែលរួមបញ្ចូលទាំងសិទ្ធិរបស់មនុស្សនិងសហគមន៍កំពុងរស់ក្នុងភាពក្រីក្រផងដែរ។ រដ្ឋគួរចាត់វិធានការបន្ថែមដើម្បីការពារប្រឆាំងនឹងការបំពានសិទ្ធិមនុស្សដែលបង្កឡើងដោយសហគ្រាសធុរកិច្ច ដែលមានរដ្ឋជាម្ចាស់ឬគ្រប់គ្រងដោយរដ្ឋ ឬដែលទទួលបានការគាំទ្រ និងសេវាកម្មច្រើនពីទីភ្នាក់ងាររដ្ឋ។

100. តួអង្គមិនមែនរដ្ឋ រួមបញ្ចូលទាំងសហគ្រាសធុរកិច្ច មានការទទួលខុសត្រូវ នៅក្នុងកម្រិតអប្បបរមាបំផុត ក្នុងការគោរពសិទ្ធិមនុស្ស ដែលមានន័យថា ដើម្បីជៀសវាងការបង្កឬការរួមចំណែកដល់ផលប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរតាមរយៈសកម្មភាព ផលិតផល ឬសេវាកម្មរបស់ខ្លួន និងត្រូវដោះស្រាយផលប៉ះពាល់ទាំងអស់នេះ នៅពេលដែលវាកើតឡើង។

101. ធុរកិច្ចគួរអនុម័តនូវការប្តេជ្ញាចិត្តផ្នែកគោលនយោបាយច្បាស់លាស់មួយ ដើម្បីគោរពសិទ្ធិមនុស្ស ដោយរួមបញ្ចូលទាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងត្រូវអនុវត្តដំណើរការប្រព្រឹត្តត្រឹមត្រូវតាមសិទ្ធិមនុស្ស ដើម្បីកំណត់និងប៉ាន់ប្រមាណទៅលើផលប៉ះពាល់ជាក់ស្តែងឬជាសក្តានុពលណាមួយ ទៅលើសិទ្ធិមនុស្ស ដែលបង្កឡើងដោយសកម្មភាពផ្ទាល់របស់ក្រុមហ៊ុននិងដោយដៃគូធុរកិច្ចដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនោះ។ ធុរកិច្ច គួរទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរពីសកម្មភាពរបស់ខ្លួនទៅលើសិទ្ធិរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ ដោយរួមបញ្ចូលទាំងការបង្កើតឬការចូលរួមនៅក្នុងយន្តការបណ្តឹងកម្រិតប្រតិបត្តិការ សម្រាប់បុគ្គលនិងសហគមន៍ដែលប្រឈមមុខនឹងផលប៉ះពាល់បែបនេះ។

102. កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សដោយភាគីទីបី តម្រូវឱ្យចាត់វិធានការដើម្បីទប់ស្កាត់ ស៊ើបអង្កេត ដាក់ទណ្ឌកម្ម និងផ្តល់ដំណោះស្រាយចំពោះការរំលោភបំពានណាមួយតាមរយៈគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ ឬការជំនុំជម្រះក្តី ប្រកបដោយប្រសិទ្ធភាព។ រដ្ឋត្រូវតែធានាថា អ្នកទទួលរងផលប៉ះពាល់ពីការរំលោភបំពានទាក់ទងនឹងធុរកិច្ច អាចទទួលបាននូវការផ្តល់សំណងដំណោះស្រាយឆាប់រហ័ស បង្កលក្ខណៈងាយស្រួលនិងមានប្រសិទ្ធភាព រាប់បញ្ចូលទាំងមធ្យោបាយចាំបាច់នាំទៅរកដំណោះស្រាយ

តាមផ្លូវតុលាការ និងការទទួលខុសត្រូវក្រៅប្រព័ន្ធតុលាការ ហើយនិងយន្តការបណ្ដឹងផ្សេងទៀត។ វាគួររួមបញ្ចូលនូវការដោះស្រាយចំពោះឧបសគ្គនានាដែលរារាំងការទទួលបានយុត្តិធម៌ មានដូចជាឧបសគ្គខាងផ្លូវច្បាប់ ឧបសគ្គខាងការអនុវត្ត និងឧបសគ្គផ្នែកនីតិវិធី និងរួមទាំងការរើសអើងដែលរារាំងមនុស្សកំពុងរស់ក្នុងភាពក្រីក្រ ពីការប្រើប្រាស់និងការទទួលអត្ថប្រយោជន៍ពីវិធានការទាំងអស់នេះ ដោយសារតែរបាំងវប្បធម៌ សង្គម កាយសម្បទា ឬហិរញ្ញវត្ថុ។

## VIII. ការអនុវត្តនិងការតាមដាន

103. ការអនុវត្តដោយជោគជ័យចំពោះគោលការណ៍ណែនាំនេះ គឺអាស្រ័យលើការដាក់ចេញឱ្យទៅជាយុទ្ធសាស្ត្រថ្នាក់ជាតិស្ដីពី ការកាត់បន្ថយភាពក្រីក្រនិងសិទ្ធិមនុស្ស និងទៅលើការបង្កើតយន្តការតាមដាននិងពង្រឹងការអនុវត្តនៅក្នុងស្រុកប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំង តាមរយៈស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែលបង្កើតឡើងស្របតាមគោលការណ៍ទាក់ទងនឹងឋានៈស្ថាប័នជាតិសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ក្រុងប៉ារីស)។

104. រដ្ឋគួរអនុម័ត និងអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិគ្រប់ជ្រុងជ្រោយ និងផែនការសកម្មភាពដើម្បីលុបបំបាត់ភាពក្រីក្រ ដោយមានចែងពីលក្ខខណ្ឌសិទ្ធិមនុស្ស។ ផែនការសកម្មភាពជាតិ គួរដាក់បញ្ចូលនៅគ្រប់កម្រិតរដ្ឋបាលទាំងអស់ ព្រមទាំងកំណត់រកឱ្យឃើញនិងដាក់ចេញនូវអាទិភាពឱ្យស្របតម្រូវការរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ។ ផែនការទាំងនេះ ត្រូវតែផ្ដល់ជាក្របខណ្ឌមួយសម្រាប់សេវាសាធារណៈនិងកម្មវិធីសាធារណៈទាំងអស់ ក្នុងការគោរព ការការពារ និងបំពេញសិទ្ធិមនុស្សរបស់មនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងចែងអំពីសូចនាករ ស្តង់ដារសម្រាប់វាស់វែង និងតារាងពេលវេលា ដែលអាចតាមដានទៅលើការរីកចម្រើនបាន។ យុទ្ធសាស្ត្រនិងផែនការ គួរតែបង្កើតឡើង និងត្រួតពិនិត្យឡើងវិញតាមកាលកំណត់ តាមរយៈដំណើរការដែលមានតម្លាភាព បរិយាប័ន្ន មានការចូលរួម និងការគិតគូដល់យេនឌ័រ។ ដំណើរការដែលយុទ្ធសាស្ត្រនិងផែនការសកម្មភាពត្រូវបានបង្កើត និងខ្លឹមសាររបស់វា គួរផ្ដោតការយកចិត្តទុកដាក់ជាពិសេសទៅដល់ក្រុមងាយរងគ្រោះនិងក្រុមដែលគេផាត់ចេញពីសង្គម។ រដ្ឋគួរកំណត់និងផ្សព្វផ្សាយពីឱកាសសម្រាប់ការចូលរួម និងជាព័ត៌មាន អំពីវិធានការគោលនយោបាយដែលបានស្នើឡើង ហើយគួរផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងតាមវិធីដែលបង្កលក្ខណៈងាយស្រួល។

105. រដ្ឋគួរផ្ដល់ទំនុកចិត្តដល់ស្ថាប័នថ្នាក់ជាតិឯករាជ្យមួយ ក្នុងការធ្វើកិច្ចការតាមដានពីទិដ្ឋភាពបែបបរិមាណវិស័យ និងគុណវិស័យ អំពីភាពក្រីក្រតាមទស្សនៈសិទ្ធិមនុស្ស និងផ្ដល់បណ្ដុំទិន្នន័យបែងចែកតាមប្រភេទ ដែលចាំបាច់សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព។ ព័ត៌មានត្រូវប្រមូលនិងសិក្សាស្របតាមបទដ្ឋានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ក្នុងគោលបំណងដើម្បីការពារសិទ្ធិមនុស្សនិងធានាឱ្យមានការរក្សាការសម្ងាត់ និងការគោរពឯកជនភាព។

106. ដៃគូអភិវឌ្ឍន៍ដែលជាទីភ្នាក់ងារឯកទេសរបស់ប្រព័ន្ធអង្គការសហប្រជាជាតិនិងអង្គការថ្នាក់តំបន់ ត្រូវបានលើកទឹកចិត្តឱ្យគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនេះ ដោយមានរួមបញ្ចូលទាំងកិច្ចសហប្រតិបត្តិការអឌ្ឍគោលខាងត្បូង។ ការគាំទ្របែបនេះអាចរួមបញ្ចូលកិច្ចសហប្រតិបត្តិការបច្ចេកទេស ជំនួយហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការចែករំលែកចំណេះដឹង ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្ទេរបច្ចេកវិទ្យា។

107. ការអនុវត្តផែនការសកម្មភាពជាតិ ត្រូវតែធ្វើឱ្យមានគណនេយ្យភាពពេញលេញចំពោះមនុស្សកំពុងរស់ក្នុងភាពក្រីក្រ និងត្រូវតែតាមដានដោយតួអង្គជាច្រើន ដូចជាស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ តុលាការ គណៈកម្មការរដ្ឋសភា និងយន្តការសិទ្ធិមនុស្សថ្នាក់តំបន់និងអន្តរជាតិ។ មនុស្សកំពុងរស់ក្នុងភាពក្រីក្រ គួរតែអាចចូលរួមក្នុងការរៀបចំបង្កើត និងអនុវត្តយន្តការតាមដានទាំងអស់នេះដែរ។ រដ្ឋគួរលើកទឹកចិត្តឱ្យមានយន្តការគណនេយ្យភាពសង្គមពីក្រោមឡើងទៅលើ ដូចជាបណ្ណរាយការណ៍ព័ត៌មានពលរដ្ឋ សវនកម្មសង្គម និងប្រព័ន្ធថវិកាដែលមានលក្ខណៈចូលរួម។

IX. ការបកស្រាយ

108. គោលការណ៍ណែនាំទាំងអស់នេះ មិនគួរត្រូវបានបកស្រាយថាជាការដាក់កំហិត ផ្លាស់ប្តូរ ឬបុរេវិនិច្ឆ័យទៅលើសិទ្ធិដែលបានទទួលស្គាល់ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តង់ដារពាក់ព័ន្ធ ឬសិទ្ធិដែលស្របនឹងច្បាប់អន្តរជាតិដូចដែលបានទទួលស្គាល់នៅក្រោមច្បាប់ជាតិណាមួយនោះទេ។

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ស៊ុយអែត
Sverige

# Guiding Principles on Extreme Poverty and Human Rights

September 2023

# Guiding Principles on Extreme Poverty and Human Rights

# Contents

**Preface** ........ 3
**Frequently Asked Questions** ........ 4
**I. Introduction to Extreme Poverty and Human Rights** ........ 4
**II. The United Nations Guiding Principles on Extreme Poverty and Human Rights** ........ 6
**III. Applying the Guiding Principles in Cambodia** ........ 7
**IV. Additional Information** ........ 7
**The Guiding Principles on Extreme Poverty and Human Rights** ........ 8

# Preface

